# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០២-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៣៦ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ជុងចេ** (LEE JEUNG JAE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងដេយុង (Dea Jon ) សាធារណរដ្ឋកូរ៉េ ដោយប្ដូរឈ្មោះជា **លី ខេមរិន** (LEE KHEMARIN) ៧០៨០

០២-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៣៧ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្សង់លុច ប៉ូដឺវ៉ាំង** (JEAN-LUC POTDEVIN) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅផ្លូវហ្សេណេវ៉ាល់ ដឺហ្គោល ហ្សង់លុច សាធារណរដ្ឋបារាំង ដោយប្ដូរឈ្មោះជា **សុខ សាន្តនិរន្តរ៍** (SOK SANNIRHONN) ៧០៨១

០៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៤៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ វ៉ៃ** (LIU WEI) ជនជាតិចិន សញ្ជាតិចិន កើតនៅ ស្រុកហ៊ឺជី ខេត្តសានតុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្ដូរឈ្មោះជា **លីវ វីនសិន** (LIU VINCENT) ៧០៨២

១៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី យ៉ុងជីន** (LEE YONGJIN) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្ដូរឈ្មោះជា **លី ដានីញែល** (LEE DANIE L) ៧០៨៣

១៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជួង ហ្គាន់ណា** (CHUONG GANNA) ជនជាតិអ៊ុយក្រែន សញ្ជាតិរុស្ស៊ី កើតនៅក្រុងខារ៉ាកូវ ប្រទេសអ៊ុយក្រែន ៧០៨៤

២១-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៨៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន ចំនួន ៣៥១ រូប ចំណុះអគ្គបញ្ជាការដ្ឋាន មានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ៧០៨៥

២៤-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៩១ ស្ដីពី ការតែងតាំងឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** *ប្រធានរដ្ឋសភានីតិកាលទី ៤* មានឋានៈស្មើ រដ្ឋលេខាធិការ ៧០៩៥

# II_រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

២៧-៨-២០១០ -អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៧០៩៦
២៧-៨-២០១០ -អនុក្រឹត្យលេខ ១០៥ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៧០៩៨
៣០-៨-២០១០ -អនុក្រឹត្យលេខ ១០៦ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៧១០០
៣០-៨-២០១០ -អនុក្រឹត្យលេខ ១០៧ អនក្រ.បក ស្ដីពី ការបង្កើតគណៈកម្មាធិការជាតិបរិស្ថាន និង សុខភាព ៧១០២
៣០-៨-២០១០ -អនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្ដីពី ការកំណត់អត្រា និង បែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ ៧១០៧
២៥-៨-២០១០ -អនុក្រឹត្យលេខ ៨៩៧ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧១១៤
២៥-៨-២០១០ -អនុក្រឹត្យលេខ ៨៩៨ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១១៥
២៥-៨-២០១០ -អនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១១៦
២៥-៨-២០១០ -អនុក្រឹត្យលេខ ៩០០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១១៧
២៥-៨-២០១០ -អនុក្រឹត្យលេខ ៩០១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១១៨
២៥-៨-២០១០ -អនុក្រឹត្យលេខ ៩០២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១១៩
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៣ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៧១២១
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១២២
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៧១២៣
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧១២៤
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧១២៥
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧១២៧
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩០៩ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៧១៣៦
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩១០ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៧១៤០
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩១១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧១៤១
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩១២ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧១៤២
២៦-៨-២០១០ -អនុក្រឹត្យលេខ ៩១៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧១៤៤
២៨-៨-២០១០ -អនុក្រឹត្យលេខ ៩១៤ អនក្រ.តត ស្ដីពី ការតែងតាំងក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាកម្ពុជា ៧១៤៧

៣០-៨-២០១០ -អនុក្រឹត្យលេខ ៩១៥ អនក្រ.តត ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាល ប្រៃសណីយ៍កម្ពុជា ៧១៤៩
៣០-៨-២០១០ -អនុក្រឹត្យលេខ ៩១៦ អនក្រ.តត ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ ៧១៥១

## ២. សេចក្តីសម្រេច

២៤-៨-២០១០ -សេចក្តីសម្រេចលេខ ៤៤ សសរ ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៧១៥២

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៩-៨-២០១០ -ប្រកាសលេខ ៥៦៩ សហវ.ប្រក ស្តីពី ការត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូន ៧១៥៣
១៩-៨-២០១០ -ប្រកាសលេខ ៥៧០ សហវ.ប្រក ស្តីពី នីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ ៧១៦០
១៩-៨-២០១០ -ប្រកាសលេខ ៥៧១ សហវ.ប្រក ស្តីពី នីតិវិធី នៃការបង់ពន្ធ និង អាករ លើទំនិញនាំចេញ និង ទំនិញនាំចូល ៧១៦៣

### ២. ធនាគារជាតិ នៃ កម្ពុជា

២៥-៨-២០១០ -ប្រកាសលេខ ធ ៩. ០១០.១៥០ ប្រក ស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ៧១៦៧

### ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-៨-២០១០ -ប្រកាសលេខ ៦៨៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាង ឈីង អ៊ីមប្រយឌើរ បង្កើតរោងចក្រ ប៉ាក់សម្លៀកបំពាក់ ៧១៧៧
១៨-៨-២០១០ -ប្រកាសលេខ ៦៨៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អង្គរ យៃនរើស ខូអិលធីឌី បង្កើតរោងចក្រ ផលិត ស៊ុមរូបថត-ស៊ុមផ្ទាំងគំនូរ ៧១៨១

### ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១៨-៨-២០១០ -ប្រកាសលេខ ១៧៧ កប/ប្រក ស្តីពី សមាសភាព និង ការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ៧១៨៥
២៣-៨-២០១០ -ប្រកាសលេខ ១៨៧ កប/ប្រក ស្តីពី សមាសភាព និង ការតែងតាំងសមាសភាពគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ៧១៩០

### ៥. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២២-១២-២០០៩-លិខិតបញ្ជាក់លេខ ៤៩៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ដាគសាន មេគាស៊ីស (ខេមបូឌា) ៧១៩២

២២-១២-២០០៩-លិខិតបញ្ជាក់លេខ ៤៩៧៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាលុយមីណា (ខេមបូឌា-វៀតណាម)** ៧១៩៤

២៣-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៩៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ូខវឿង ឌីជារ៉េតនៈ អ៊ិនធើណេសិនណល ខូ អិលធីឌី** ៧១៩៦

២៣-១២-២០០៩ -លិខិតបញ្ជាក់លេខ ៥០០០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូលីដេ អ៊ីន (ខេមបូឌា)** ៧១៩៨

២៤-១២-២០០៩ -លិខិតបញ្ជាក់លេខ ៥០០៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមខាប់ភីថល** ៧២០០

២៤-១២-២០០៩ -លិខិតបញ្ជាក់លេខ ៥០១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល ហ្គ្រីន អេនើជី ខូ អិលធីឌី** ៧២០២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៦៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ជុងចេ** (LEE JEUNG JAE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៦១ នៅទីក្រុងដេយុង (Dea Jon) សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **លី ខេមរិន** (LEE KHEMARIN) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣/ល. ១០០៩. ៦៥១

លេខៈ ៥៧៨ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១០

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល**

**ស៊ិន ឌីនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្សង់លុច ប៉ូដឺវាំង** (JEAN-LUC POTDEVIN) ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៤៩ នៅផ្លូវហ្សេណេរ៉ាល់ ដឺហ្គោល ហ្សង់លុច សាធារណរដ្ឋបារាំង ដោយប្តូរឈ្មោះជា **សុខ សាន្តនិរន្តរ៍** (SOK SANNNIRHONN) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១០០៩.៦៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១០

លេខ: ៥៧៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ជិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ វ៉ៃ** (LIU WEI) ជនជាតិចិន សញ្ជាតិចិន កើត ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៦១ នៅស្រុក ហ៊ីជី ខេត្តសានតុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **លីវ វីនសិន** (LIU VINCENT ) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.១០០៩.៦៥៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១០*

**លេខៈ ៥៩៧ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១០
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible] ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី យ៉ុងជីន** (LEE YONGJIN) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៦៤ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **លី ដានីញ៉ែល** (LEE DANIEL) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១០០៨. ៦៩៦

លេខ: ៦៦៧ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់អ្នកស្រី **ជួង ឃ្នាន់ណា** (CHUONG GANNA) ជនជាតិអ៊ុយក្រែន សញ្ជាតិរុស្ស៊ី កើតថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៧៩ នៅក្រុងខាក៉ូវ ប្រទេសអ៊ុយក្រែន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ២០០៨. ៦៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០*

លេខៈ ៦១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានឧត្តមមិជាតិសាសនា រត្នខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ
នាយទាហាន ចំនួន ៣៥១រូប ចំណុះអគ្គបញ្ជាការដ្ឋាន មានស្នាដៃល្អ និង
គុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិកន្លងមក

នូវ

**ក.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-ឧត្តមសេនីយ៍ត្រី **ព្រហ្ម សំា** អត្តលេខ ០០០៣៨៤
២-ឧត្តមសេនីយ៍ត្រី **ព្រហ្ម ពុធ** អត្តលេខ ០០០៣៨៥
៣-ឧត្តមសេនីយ៍ត្រី **ស៊ិន លីម** អត្តលេខ ០០២៩៧២
៤-ឧត្តមសេនីយ៍ត្រី **សន ស៊ា** អត្តលេខ ០០៩៣៨៨
៥-ឧត្តមសេនីយ៍ត្រី **វី សុត្ថាវុទ្ធ** អត្តលេខ ០០០៥៩៦
៦-ឧត្តមសេនីយ៍ត្រី **ឈាន ធន** អត្តលេខ ០០១០០៤
៧-ឧត្តមសេនីយ៍ត្រី **អ៊ុំង លាង** អត្តលេខ ០០៤៣៥៤
៨-ឧត្តមសេនីយ៍ត្រី **សុខ សាន្ត** អត្តលេខ ០០០៣៨៨
៩-ឧត្តមសេនីយ៍ត្រី **សំរិទ្ធ សារ៉េត** អត្តលេខ ០០១០០៦
១០-ឧត្តមសេនីយ៍ត្រី **ឈុំ ខេង** អត្តលេខ ០០១០០៥

**ខ.គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

ឧត្តមសេនីយ៍ទោ **អ៊ុយ សុភាព** អត្តលេខ ០០០១៤០

**គ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា:**

១-ឧត្តមសេនីយ៍ត្រី **ជួន ធឿន** អត្តលេខ ០០២៥៩៨
២-វរសេនីយ៍ឯក **ហ៊ី សារ៉េន** អត្តលេខ ០០២៩៧១
៣-វរសេនីយ៍ឯក **សុខ ចំរើន** អត្តលេខ ០០២៩៧០
៤-វរសេនីយ៍ឯក **ហ៊ាង សាគួន** អត្តលេខ ០០២៩៧៣
៥-វរសេនីយ៍ឯក **គង់ វណ្ណៈ** អត្តលេខ ០០៤៩៨០
៦-វរសេនីយ៍ឯក **ឱម ហុង** អត្តលេខ ០៣០៨៦៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧-វរសេនីយ៍ឯក ម៉ោគ្គ សុវណ្ណ អត្តលេខ ០០៨៩៧៩
៨-វរសេនីយ៍ឯក យូច ស៊ីផា អត្តលេខ ០១០០០៩
៩-វរសេនីយ៍ឯក ភ្លុំ ប៊ុនរឿន អត្តលេខ ០១០០០៨
១០-វរសេនីយ៍ឯក វ៉ុត្ត ស៊ីថា អត្តលេខ ០១០០១៨
១១-វរសេនីយ៍ឯក នេព គត់ អត្តលេខ ០០៤២០៣
១២-វរសេនីយ៍ឯក ហ៊ាំ ចាន់បូរ អត្តលេខ ០១០០២៤
១៣-វរសេនីយ៍ឯក ចាន់ សារឿន អត្តលេខ ០០៣៥១១
១៤-វរសេនីយ៍ឯក ឡោម ចេក អត្តលេខ ០០១០០១
១៥-វរសេនីយ៍ឯក ហាម ម៉ច់ អត្តលេខ ០១០០៣៣
១៦-វរសេនីយ៍ឯក ស រីណា អត្តលេខ ០១០០២១
១៧-វរសេនីយ៍ឯក ហាម ប៊ុនហួត អត្តលេខ ០២៥៧០៣
១៨-វរសេនីយ៍ឯក ម៉ៅ សារិន អត្តលេខ ០០២៩៨១
១៩-វរសេនីយ៍ឯក ពុធ ចន្ធូ អត្តលេខ ០១២៩២៩
២០-វរសេនីយ៍ឯក ឌី សារិន អត្តលេខ ០០២១១០
២១-វរសេនីយ៍ឯក សុខ វ៉ាន់ អត្តលេខ ០០៣៥១៣
២២-វរសេនីយ៍ឯក ព្រហ្ម វៃ អត្តលេខ ០១០០២៨
២៣-វរសេនីយ៍ឯក តូច ពឿន អត្តលេខ ០០២៩៨០
២៤-វរសេនីយ៍ឯក យឿយ សារ៉ុន អត្តលេខ ០០៣៥១២
២៥-វរសេនីយ៍ឯក ឆូ ជួន អត្តលេខ ០០៤៨១៩
២៦-វរសេនីយ៍ឯក ខ៊ែត នន អត្តលេខ ០០៤៨២៦
២៧-វរសេនីយ៍ឯក ស្រី ធី អត្តលេខ ០០៤៨២០
២៨-វរសេនីយ៍ឯក សេង សាន្ត អត្តលេខ ០០៤៨២៣
២៩-វរសេនីយ៍ឯក ដូ ឌិន អត្តលេខ ០០៤៨៣៣
៣០-វរសេនីយ៍ឯក ឡៅ ហាន អត្តលេខ ០០៣១៨៧
៣១-វរសេនីយ៍ឯក និត្យ ឌីម៉ង អត្តលេខ ០១២៩៧៩
៣២-វរសេនីយ៍ឯក លឹម ជាហេង អត្តលេខ ០១១៥៣២
៣៣-វរសេនីយ៍ឯក ធី សេរីវុឌ្ឍ អត្តលេខ ០២៥៦៦៨
៣៤-វរសេនីយ៍ឯក ទ៉ា នាង អត្តលេខ ០០៣៨១៤

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ:**

១-វរសេនីយ៍ឯក កែវ នាង អត្តលេខ ០០២០០៨
២-វរសេនីយ៍ឯក សុទ្ធ ស៊ិនសំបូរ អត្តលេខ ០០៩៨៨២
៣-វរសេនីយ៍ទោ សៅ ផេង អត្តលេខ ០១៦៨៦៥
៤-វរសេនីយ៍ទោ ញ៉ែម សាឡឿន អត្តលេខ ០០៨៨២២
៥-វរសេនីយ៍ទោ យូ សម្បត្តិ អត្តលេខ ០១៦៨៩០
៦-វរសេនីយ៍ទោ ព្រហ្ម ពៅ អត្តលេខ ០២៨៨៨៩
៧-វរសេនីយ៍ទោ ព្រុំ សារ៉ន អត្តលេខ ០១០០២៥
៨-វរសេនីយ៍ទោ នុន គីមឈន់ អត្តលេខ ០០៣៣១៨
៩-វរសេនីយ៍ទោ ឡឿន គង់ អត្តលេខ ០១៩០៦០
១០-វរសេនីយ៍ទោ អ៊ុក សារិន អត្តលេខ ០៣០២៩៨
១១-វរសេនីយ៍ទោ អ៊ុម ផល្លា អត្តលេខ ០២៩៧១៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

១២-វរសេនីយ៍ទោ ស៊ូ សារិន្ទ អត្តលេខ ០១៧៧៨៧
១៣-វរសេនីយ៍ទោ អ៊ុក ម៉ាណី អត្តលេខ ០១៩១៥០
១៤-វរសេនីយ៍ទោ អ៊ុន សៀងហៃ អត្តលេខ ០១០០២០
១៥-វរសេនីយ៍ទោ អ៊ុក សួន អត្តលេខ ០១០០០៧
១៦-វរសេនីយ៍ទោ គួក ចន្ធូ អត្តលេខ ០១០០២២
១៧-វរសេនីយ៍ទោ ប៉ែន សារ៉េត អត្តលេខ ០១៩១០៨
១៨-វរសេនីយ៍ទោ លិន យន្ត អត្តលេខ ០១០០១៣
១៩-វរសេនីយ៍ទោ ស្រី សាញ់ អត្តលេខ ០០៥០៦៧
២០-វរសេនីយ៍ទោ ហាឡូ តារា អត្តលេខ ០១២០៨២
២១-វរសេនីយ៍ទោ អ៊ិន ស៊ីន អត្តលេខ ០១០០២៣
២២-វរសេនីយ៍ទោ អ៊ុន នួច អត្តលេខ ០១៩១៣៣
២៣-វរសេនីយ៍ទោ ប៉ាង សុផល អត្តលេខ ០៨១៧៦៧
២៤-វរសេនីយ៍ទោ ភ្លួយ ពិសិដ្ឋ អត្តលេខ ០១៩១២៧
២៥-វរសេនីយ៍ទោ ពុធ ជឿយ អត្តលេខ ០០២៩៧៨
២៦-វរសេនីយ៍ទោ ស៊ឹម រៀម អត្តលេខ ០១៩១៣៧
២៧-វរសេនីយ៍ទោ អ៊ុក សាខន អត្តលេខ ០១៩១០២
២៨-វរសេនីយ៍ទោ ប៊ុត ហុក អត្តលេខ ០១០០១២
២៩-វរសេនីយ៍ទោ ចាច់ សុវ៉ែន អត្តលេខ ០១០០១១
៣០-វរសេនីយ៍ទោ ភាន់ ភៀន អត្តលេខ ០០៨៩៨២
៣១-វរសេនីយ៍ទោ យួង សាគុណា អត្តលេខ ០១០០២៨
៣២-វរសេនីយ៍ទោ ឡៀង យុទ្ធហ៊ាន អត្តលេខ ០១៩១៨៣
៣៣-វរសេនីយ៍ទោ នួន សុផល អត្តលេខ ០១០០១០
៣៤-វរសេនីយ៍ទោ ស្មួន យក់ អត្តលេខ ០១៩១៨៧
៣៥-វរសេនីយ៍ទោ ប៊ុន ច័ន្ទថា អត្តលេខ ០០៩៩៨៣
៣៦-វរសេនីយ៍ទោ ព្រិល សារឿន អត្តលេខ ០១៩១៨៦
៣៧-វរសេនីយ៍ទោ ចាន់ ជាន អត្តលេខ ០១០០៣៩
៣៨-វរសេនីយ៍ទោ សុខ សារ៉ុន អត្តលេខ ០១០០៣៨
៣៩-វរសេនីយ៍ទោ អ៊ាន់ សិទ្ធ អត្តលេខ ០០២៩៧៦
៤០-វរសេនីយ៍ទោ ឆេង យ៉ានី អត្តលេខ ០០២៩៧៧
៤១-វរសេនីយ៍ទោ ឥន សារឿន អត្តលេខ ០១៩១៨២
៤២-វរសេនីយ៍ទោ ហួន ហ៊ាន អត្តលេខ ០១៩១៧២
៤៣-វរសេនីយ៍ទោ នួន លឹម អត្តលេខ ០១០០៤២
៤៤-វរសេនីយ៍ទោ កែវ ហាន់ អត្តលេខ ០១០០៥២
៤៥-វរសេនីយ៍ទោ អ៊ួង ទិមុល អត្តលេខ ០១០០៤៥
៤៦-វរសេនីយ៍ទោ ឆាម ឡាំ អត្តលេខ ០១០០៨៨
៤៧-វរសេនីយ៍ទោ ស៊ូ ម៉ៅ អត្តលេខ ០១០០៤៤
៤៨-វរសេនីយ៍ទោ សោមហួច អត្តលេខ ០១៩១៨៨
៤៩-វរសេនីយ៍ទោ អៀង គី អត្តលេខ ០០៨៩៨៣
៥០-វរសេនីយ៍ទោ ចឡូ កុសល អត្តលេខ ០០៨២០២
៥១-វរសេនីយ៍ទោ សោម សម្បត្តិ អត្តលេខ ០១០០៣៦
៥២-វរសេនីយ៍ទោ ហាឡូ សុផន អត្តលេខ ០១០០១៥

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥៣-វរសេនីយ៍ទោ ម៉ៅ សុខុម អត្តលេខ ០១០០១៩
៥៤-វរសេនីយ៍ទោ ផុន ឡុង អត្តលេខ ០១០០៨៧
៥៥-វរសេនីយ៍ទោ គូ ផន អត្តលេខ ០១០០៨១
៥៦-វរសេនីយ៍ទោ ជុំ ផាន អត្តលេខ ០០៤២០៤
៥៧-វរសេនីយ៍ទោ កែម ខុម អត្តលេខ ០០៤២០៥
៥៨-វរសេនីយ៍ទោ គួច ឌុន្នារ៉ា អត្តលេខ ០២៣៩១៦
៥៩-វរសេនីយ៍ទោ ហេង ចាន់មុន្នី អត្តលេខ ០១៥២២៣
៦០-វរសេនីយ៍ទោ សំ ចន្ថា អត្តលេខ ០០៩៤៧០
៦១-វរសេនីយ៍ទោ សាត ម៉េងហួរ អត្តលេខ ០១៦៤៨៦
៦២-វរសេនីយ៍ត្រី មួន សុខឌី អត្តលេខ ០២១៧៤៩
៦៣-វរសេនីយ៍ត្រី ច័ន្ទ សុធី អត្តលេខ ១៥៦៤៩៩

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា:**

១-វរសេនីយ៍ឯក ជា ផាន អត្តលេខ ០០២១៧៣
២-វរសេនីយ៍ទោ សុខ តន្ត្រា អត្តលេខ ០២៥៧៣៨
៣-វរសេនីយ៍ទោ ម៉ាន់ រះសក្តិ អត្តលេខ ០២២៩១៦
៤-វរសេនីយ៍ត្រី ប៉ាក់ កុសល អត្តលេខ ០៦៩៧២៣
៥-វរសេនីយ៍ត្រី នៅ ចាន់នី អត្តលេខ ០២៩៦២៧
៦-វរសេនីយ៍ត្រី ពៅ ពិសី អត្តលេខ ០២៩៦៣១
៧-វរសេនីយ៍ត្រី ម៉ាន់ វណ្ណៈ អត្តលេខ ០១៩១១២
៨-វរសេនីយ៍ត្រី ម៉ូ ណាល់ អត្តលេខ ០២៩៦២៩
៩-វរសេនីយ៍ត្រី ឡឹក សារ៉ាន់ អត្តលេខ ០១៩១១៤
១០-វរសេនីយ៍ត្រី ហាឡ្យ សារិន អត្តលេខ ១៥៧០០៩
១១-វរសេនីយ៍ត្រី ឈុំ សាមឿន អត្តលេខ ០១៩១១៥
១២-វរសេនីយ៍ត្រី អ៊ាញ ណារី អត្តលេខ ០១២០៧០
១៣-វរសេនីយ៍ត្រី នៅ ណាត អត្តលេខ ០២៩៦៧៧
១៤-វរសេនីយ៍ត្រី មាស ផុល អត្តលេខ ០២៩៦៣០
១៥-វរសេនីយ៍ត្រី មុត ស៊ីថា អត្តលេខ ០២៤៤៨៦
១៦-វរសេនីយ៍ត្រី ហ៊ឹម ណាល់ អត្តលេខ ១៥៦៦៣៥
១៧-វរសេនីយ៍ត្រី ចិន ស្រស់ អត្តលេខ ០៣៩៣៨៦
១៨-វរសេនីយ៍ត្រី អៀម ចាសនា អត្តលេខ ០២៩៦៥០
១៩-វរសេនីយ៍ត្រី មុត សុភឿន អត្តលេខ ០២៤៤៤៨
២០-វរសេនីយ៍ត្រី លី ជុន អត្តលេខ ០១៩១៣០
២១-វរសេនីយ៍ត្រី ឈុំ ហួរ អត្តលេខ ១៥៦៩៦២
២២-វរសេនីយ៍ត្រី សាយ ខនថា អត្តលេខ ០១៩១៥៣
២៣-វរសេនីយ៍ត្រី អ៊ុក សារ៉េត អត្តលេខ ០២៩៦៥៩
២៤-វរសេនីយ៍ត្រី ប៉ូច មុនី អត្តលេខ ០២៩៦៥៦
២៥-វរសេនីយ៍ត្រី ផូ រិទ្ធី អត្តលេខ ០២៤៤៩០
២៦-វរសេនីយ៍ត្រី ពាញ សុផន អត្តលេខ ០១៩១៤៤
២៧-វរសេនីយ៍ត្រី កែវ សំណាង អត្តលេខ ០១៩១០៦
២៨-វរសេនីយ៍ត្រី ទៀម សារី អត្តលេខ ០១៩១៣៦
២៩-វរសេនីយ៍ត្រី អ៊ុំ យិន អត្តលេខ ០២៩៦៥៧

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣០-វរសេនីយ៍ត្រី សោម សុខឿន អត្តលេខ ០៤៣៤២៧
៣១-វរសេនីយ៍ត្រី យឹម សុវណ្ណា អត្តលេខ ០១៩១២៥
៣២-វរសេនីយ៍ត្រី អាន ឌុច អត្តលេខ ០២៩៦៥៣
៣៣-វរសេនីយ៍ត្រី ម៉ាយ ហ៊ាន អត្តលេខ ០១៩១០៧
៣៤-វរសេនីយ៍ត្រី សោម ឡុច អត្តលេខ ០២៤៤៨៤
៣៥-វរសេនីយ៍ត្រី ស្រី ជៀន អត្តលេខ ០១០០២៧
៣៦-វរសេនីយ៍ត្រី ពន់ ពៃ អត្តលេខ ០១៩១៤៨
៣៧-វរសេនីយ៍ត្រី ឃួន សុខា អត្តលេខ ០១៩១២០
៣៨-វរសេនីយ៍ត្រី ជា ឈិន អត្តលេខ ០១៩១៩១
៣៩-វរសេនីយ៍ត្រី ម៉ា យ៉ាន អត្តលេខ ០៤១៦៨៣
៤០-វរសេនីយ៍ត្រី សោម សំអឿន អត្តលេខ ០១៩១៤៦
៤១-វរសេនីយ៍ត្រី ឈើយ ចណ្ណៈ អត្តលេខ ០១៩១៤៥
៤២-វរសេនីយ៍ត្រី ជិន អ៊ុន អត្តលេខ ០២៩៦៦១
៤៣-វរសេនីយ៍ត្រី ផុន គី អត្តលេខ ០១៩១៣៨
៤៤-វរសេនីយ៍ត្រី ចក់ មឿក អត្តលេខ ០៤១៦៧៦
៤៥-វរសេនីយ៍ត្រី ប៊ូ សៀប អត្តលេខ ០១០០៣១
៤៦-វរសេនីយ៍ត្រី ចាន់ សាត អត្តលេខ ០៤១៦៧១
៤៧-វរសេនីយ៍ត្រី យស់ ផល្លា អត្តលេខ ០២៩៦៥៤
៤៨-វរសេនីយ៍ត្រី អាន់ សៀន អត្តលេខ ១៥៦៧៦២
៤៩-វរសេនីយ៍ត្រី ថោង ឧត្តរា អត្តលេខ ០១៩១៤១
៥០-វរសេនីយ៍ត្រី ខៀវ ចាន់រស្មី អត្តលេខ ០១៩១២២
៥១-វរសេនីយ៍ត្រី ជុំ ចន អត្តលេខ ០២៩៦៤២
៥២-វរសេនីយ៍ត្រី ខួន សាខឿន អត្តលេខ ០២៩៦៤១
៥៣-វរសេនីយ៍ត្រី ផៃ សុផាត អត្តលេខ ០២៤៤៩១
៥៤-វរសេនីយ៍ត្រី ជា សុច អត្តលេខ ១០២៦៧៣
៥៥-វរសេនីយ៍ត្រី ប្រាក់ ចាន់តារា អត្តលេខ ០៤១៦៧៣
៥៦-វរសេនីយ៍ត្រី ឈុន យឿន អត្តលេខ ០១៩១៣៥
៥៧-វរសេនីយ៍ត្រី ព្រំ ម៉ៃ អត្តលេខ ០២៩៥០៣
៥៨-វរសេនីយ៍ត្រី ហាច្យ ពៅ អត្តលេខ ០០៩៩៨៤
៥៩-វរសេនីយ៍ត្រី ចាន់ សាសនា អត្តលេខ ០១៧៣៣២
៦០-វរសេនីយ៍ត្រី រស់ ផល្លី អត្តលេខ ០២៦៨៧០
៦១-វរសេនីយ៍ត្រី ពៅ ចិចិត្រា អត្តលេខ ០១៩១៤៩
៦២-វរសេនីយ៍ត្រី ជុំ ឈិន អត្តលេខ ០២៩៦៩២
៦៣-វរសេនីយ៍ត្រី អាំ សុផាន់ណា អត្តលេខ ១៥៦៨៦២
៦៤-វរសេនីយ៍ត្រី អ៊ុក ចំរើន អត្តលេខ ០១៩១១៦
៦៥-វរសេនីយ៍ត្រី នុយ នួត អត្តលេខ ០១៩១៧៧
៦៦-វរសេនីយ៍ត្រី សុខ សោភា អត្តលេខ ០១៩១៦៦
៦៧-វរសេនីយ៍ត្រី ស៊ិន សួន អត្តលេខ ០១៩១៦៧
៦៨-វរសេនីយ៍ត្រី ជឹម ធន អត្តលេខ ០១៩១៥៥
៦៩-វរសេនីយ៍ត្រី នុយ ឈន អត្តលេខ ០២៩៦៧៨
៧០-វរសេនីយ៍ត្រី ហឿន សុជាតិ អត្តលេខ ០១៩១៧៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៧១-វរសេនីយ៍ត្រី គង់ ហឿន អត្តលេខ ០១៩១៦៨
៧២-វរសេនីយ៍ត្រី លឹម សូត្រ អត្តលេខ ០២៩៦៩០
៧៣-វរសេនីយ៍ត្រី គឹម ធរៈ អត្តលេខ ០២៩៧០៨
៧៤-វរសេនីយ៍ត្រី ចាន់ សារី អត្តលេខ ០១០០៥៣
៧៥-វរសេនីយ៍ត្រី សុខ សំអាត អត្តលេខ ១០២២៦៨
៧៦-វរសេនីយ៍ត្រី ឱម សុធី អត្តលេខ ០១០០៨៦
៧៧-វរសេនីយ៍ត្រី នួន សុត្រា អត្តលេខ ០២២៨៤៨
៧៨-វរសេនីយ៍ត្រី កៅ សិទ្ធ អត្តលេខ ០១០០៨០
៧៩-វរសេនីយ៍ត្រី នួន សារឿន អត្តលេខ ០១៩១៦១
៨០-វរសេនីយ៍ត្រី អេង ត្រី អត្តលេខ ០២៩៧១២
៨១-វរសេនីយ៍ត្រី អៀម សាខុន អត្តលេខ ០២៨៦៨៣
៨២-វរសេនីយ៍ត្រី យ៉េម សម័យ អត្តលេខ ០១៩១៧៨
៨៣-វរសេនីយ៍ត្រី ឌេស ខ្មៅ អត្តលេខ ០១៩១៧៩
៨៤-វរសេនីយ៍ត្រី ជួប សុភី អត្តលេខ ០១៩១៨១
៨៥-វរសេនីយ៍ត្រី មឿង គង់ អត្តលេខ ០២៨៦៨១
៨៦-វរសេនីយ៍ត្រី ពេជ្រ សិរិទ្ធ អត្តលេខ ០១៩១៩៤
៨៧-វរសេនីយ៍ត្រី ចាក់ ផន អត្តលេខ ០១០០៣៥
៨៨-វរសេនីយ៍ត្រី ចាន់ សារ៉ា អត្តលេខ ០២៩៧៣០
៨៩-វរសេនីយ៍ត្រី យ៉េន ហឿម អត្តលេខ ០១៩១៩០
៩០-វរសេនីយ៍ត្រី អ៊ុច លឿប អត្តលេខ ០១៩២០៤
៩១-វរសេនីយ៍ត្រី ដែន មួក អត្តលេខ ០១៩១៨៣
៩២-វរសេនីយ៍ត្រី ផល រី អត្តលេខ ០២៩៧២៩
៩៣-វរសេនីយ៍ត្រី សេង អេត អត្តលេខ ០១៩១៨៩
៩៤-វរសេនីយ៍ត្រី គាំ ជីវ៉ា អត្តលេខ ០១០០៥១
៩៥-វរសេនីយ៍ត្រី គង់ ម៉ុនលាង អត្តលេខ ០២៩៧២១
៩៦-វរសេនីយ៍ត្រី លី ស៊ីវឡ្យ អត្តលេខ ០១៩១៨៥
៩៧-វរសេនីយ៍ត្រី សិទ្ធ សឿង អត្តលេខ ០១៩១៨៧
៩៨-វរសេនីយ៍ត្រី ប្រាក់ ម៉ុនលី អត្តលេខ ០២៩៧២៨
៩៩-វរសេនីយ៍ត្រី លេន ឌុន អត្តលេខ ០២២៨៤៧
១០០-វរសេនីយ៍ត្រី ទុត ឆាមចិជ្ជ័យ អត្តលេខ ០២៨៦៥៩
១០១-វរសេនីយ៍ត្រី កែវ សារ៉ាន អត្តលេខ ០១៩១៦៤
១០២-វរសេនីយ៍ត្រី ម៉ី ជួន អត្តលេខ ០២៨៤៨៥
១០៣-វរសេនីយ៍ត្រី នាង សុខុម អត្តលេខ ០២៨៤៨៧
១០៤-វរសេនីយ៍ត្រី ឆ្មា គុត អត្តលេខ ០២២៨៥១
១០៥-វរសេនីយ៍ត្រី សុខ ហួត អត្តលេខ ០២៨៦៣៣
១០៦-វរសេនីយ៍ត្រី នួន ផ្លា អត្តលេខ ០២២៨៥០
១០៧-វរសេនីយ៍ត្រី ស៊ុន រ៉ែន អត្តលេខ ០២៨៦៣២
១០៨-វរសេនីយ៍ត្រី ចាន់ បូរ៉ា អត្តលេខ ០២៨១២៦
១០៩-វរសេនីយ៍ត្រី គង់ ស៊ីខឿន អត្តលេខ ០១៩១៧៦
១១០-វរសេនីយ៍ត្រី ឈឹម សេត អត្តលេខ ០១៩១៧៥
១១១-អនុសេនីយ៍ឯក ឡេង ឌីណា អត្តលេខ ០៤៣៨៤០

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១១២-អនុសេនីយ៍ឯក ស៊ុន សិន្ធា អត្តលេខ ០៣៩៦៣៩

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិៈ**

១-វរសេនីយ៍ឯក **ពុធ ធូច** អត្តលេខ ០០២១៩៦
២-វរសេនីយ៍ទោ **ផន ម៉ិនធី** អត្តលេខ ០០៨៤៥៣
៣-វរសេនីយ៍ទោ **ភុយ លាង** អត្តលេខ ០១៨៤៨៦
៤-វរសេនីយ៍ទោ **គីម សុគន្ធី** អត្តលេខ ០២២៣៨២
៥-វរសេនីយ៍ទោ **ព្រំ ហៀង** អត្តលេខ ០១៩៤១៦
៦-វរសេនីយ៍ត្រី **ព្រាប សុផល** អត្តលេខ ០៣១៨៤០
៧-វរសេនីយ៍ត្រី **នុង រំចេក** អត្តលេខ ០៤៣៨៧០
៨-វរសេនីយ៍ត្រី **សុខ ហេង** អត្តលេខ ០២៧៨០៩
៩-វរសេនីយ៍ត្រី **ឆាំ ឈៀង** អត្តលេខ០១៨៥២២
១០-វរសេនីយ៍ត្រី **គង់ ចន្ធី** អត្តលេខ ០៤៣៤៦៣
១១-វរសេនីយ៍ត្រី **ថាន ដារិទ្ធិ** អត្តលេខ ០៥៦១៩៣
១២-វរសេនីយ៍ត្រី **គ្រួច ផល្លី** អត្តលេខ ០១៦៩៥១
១៣-វរសេនីយ៍ត្រី **ថៃ ធារ៉ា** អត្តលេខ ០៣៥១២៩
១៤-អនុសេនីយ៍ឯក **គី ថាន** អត្តលេខ ០១៩១១៣
១៥-អនុសេនីយ៍ឯក **ឃឹម ថ៉ាន់ផន** អត្តលេខ ១៥៦៦៣៤
១៦-អនុសេនីយ៍ឯក **តាជ សំបូរ** អត្តលេខ ១៥៦៩១៣
១៧-អនុសេនីយ៍ឯក **លី សាធុច** អត្តលេខ ០៨០១៤៣
១៨-អនុសេនីយ៍ឯក **គោគ សុផានី** អត្តលេខ ១០៨០៣១
១៩-អនុសេនីយ៍ឯក **សរ សុតាជ** អត្តលេខ ០២៥១៨០
២០-អនុសេនីយ៍ឯក **គោគ ចិន** អត្តលេខ ១៥៦៦៣៣
២១-អនុសេនីយ៍ឯក **ម៉ុក សារិន** អត្តលេខ ០២៩៦៤៧
២២-អនុសេនីយ៍ឯក **អ៊ឹម តា** អត្តលេខ ០១៩១២១
២៣-អនុសេនីយ៍ឯក **យូ អង** អត្តលេខ ០៧៣៤៧៤
២៤-អនុសេនីយ៍ឯក **អ៊ុក ចរណៃ** អត្តលេខ ០៣៧២៦៦
២៥-អនុសេនីយ៍ឯក **ជួប ទិរៈ** អត្តលេខ ០១២៦១០
២៦-អនុសេនីយ៍ឯក **ម៉ក់ ឈឿង** អត្តលេខ ០៣៣៩០៧
២៧-អនុសេនីយ៍ឯក **នេត គីមហាក់** អត្តលេខ ០៤៧១៣៩
២៨-អនុសេនីយ៍ឯក **ផាន់ ឈន** អត្តលេខ ០៤៧១៣៤
២៩-អនុសេនីយ៍ឯក **ញ៉ឹម ពិសិដ្ឋ** អត្តលេខ ០២៩៧៨១
៣០-អនុសេនីយ៍ឯក **ម៉ុំ ឌីណា** អត្តលេខ ០៤១៦៨០
៣១-អនុសេនីយ៍ឯក **ព្រឹង សំអូន** អត្តលេខ ០១៩១៩៥
៣២-អនុសេនីយ៍ឯក **គីម មុន្នី** អត្តលេខ ០២២៨៤៦
៣៣-អនុសេនីយ៍ឯក **នួច ណារុំ** អត្តលេខ ០២២៨៤៩
៣៤-អនុសេនីយ៍ឯក **មាន ស៊ីផា** អត្តលេខ ០២៩៦៤០
៣៥-អនុសេនីយ៍ឯក **ហ៊ីត សេងហុង** អត្តលេខ ០៣៧៣២៨
៣៦-អនុសេនីយ៍ឯក **តាំង សុខហេង** អត្តលេខ ០៤៤៦៧៤
៣៧-អនុសេនីយ៍ឯក **សាក់ ណាក់** អត្តលេខ ១៥៦៧៧៧
៣៨-អនុសេនីយ៍ឯក **មិត្ត ណៃ** អត្តលេខ ០១១៣៥៣
៣៩-អនុសេនីយ៍ឯក **ពៅ សំណាង** អត្តលេខ ០២៩៦៧១

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៤០-អនុសេនីយ៍ឯក សោម យូត អត្តលេខ ០២៩៦៧០
៤១-អនុសេនីយ៍ឯក គ្រឿង ពូន អត្តលេខ ១៥៦៦៧៤
៤២-អនុសេនីយ៍ឯក អ៊ុជ យឿន អត្តលេខ ០២៩៦៦៩
៤៣-អនុសេនីយ៍ឯក ស៊ុន សំអាត អត្តលេខ ២២៨១៥៧
៤៤-អនុសេនីយ៍ឯក ចាន់ សុថារ៉ា អត្តលេខ ២១៦៨៧៤
៤៥-អនុសេនីយ៍ឯក គ្រូច សំអាន អត្តលេខ ០២៩៦៦៧
៤៦-អនុសេនីយ៍ឯក ទឹម សុផល អត្តលេខ ០២៩៦៦៦
៤៧-អនុសេនីយ៍ឯក កេម ឡាន់ អត្តលេខ ១៥៨៦៣៦
៤៨-អនុសេនីយ៍ឯក សុខ ពេជ្រ អត្តលេខ ១៥៦៦៥៤
៤៩-អនុសេនីយ៍ឯក ម៉ុន ហាន អត្តលេខ ០៤១៦៧៥
៥០-អនុសេនីយ៍ឯក ពុយ សុជាតិ អត្តលេខ ០២៩៦៦០
៥១-អនុសេនីយ៍ឯក ហេង ដាក អត្តលេខ ០២៩៦៦២
៥២-អនុសេនីយ៍ឯក មាស គួច អត្តលេខ ០៤៤៩៤៣
៥៣-អនុសេនីយ៍ឯក គង់ ម៉ៅ អត្តលេខ ១៥៦៦៣១
៥៤-អនុសេនីយ៍ឯក ប្រាំង ម៉ាប់ អត្តលេខ ០៦៤៥៥៩
៥៥-អនុសេនីយ៍ឯក ម៉ែន ណារិទ្ធ អត្តលេខ ០៤១៦៧២
៥៦-អនុសេនីយ៍ឯក ផុន សុខហេង អត្តលេខ ០៧៩១៩៦
៥៧-អនុសេនីយ៍ឯក សីន វណ្ណៈ អត្តលេខ ០៤១៦៧៩
៥៨-អនុសេនីយ៍ឯក អោក ឡឿន អត្តលេខ ០៤១៦៧៨
៥៩-អនុសេនីយ៍ឯក ខ៉ែត ណៃ អត្តលេខ ០២៦៣៨៨
៦០-អនុសេនីយ៍ឯក អ៊ិន ហៃ អត្តលេខ ០២៩៦៦៥
៦១-អនុសេនីយ៍ឯក ផាន់ ឡឿន អត្តលេខ ០២៩៦៣៨
៦២-អនុសេនីយ៍ឯក ស៊ិន សុផាន អត្តលេខ ០២៦៦៧៣
៦៣-អនុសេនីយ៍ឯក គោក សុភ័ណ្ណា អត្តលេខ ០៧០៥៣៣
៦៤-អនុសេនីយ៍ឯក យុន រ័ត្ន អត្តលេខ ០២៩៦៣៦
៦៥-អនុសេនីយ៍ឯក សុ ម៉េត អត្តលេខ ០២៩៥០៤
៦៦-អនុសេនីយ៍ឯក សោភ ឧត្តា អត្តលេខ ០៤១៥៩៨
៦៧-អនុសេនីយ៍ឯក ម៉ូច ណារ៉ុង អត្តលេខ ០៤១៦០០
៦៨-អនុសេនីយ៍ឯក នួច ធុទ្ធី អត្តលេខ ០៤១៦៩២
៦៩-អនុសេនីយ៍ឯក គ្រឿង ឌីន អត្តលេខ ០៦៤៦៣៦
៧០-អនុសេនីយ៍ឯក ទឹម នុន អត្តលេខ ០២៩៦៨០
៧១-អនុសេនីយ៍ឯក ឡឹង ចាន់រ៉ា អត្តលេខ ០២៩៧០០
៧២-អនុសេនីយ៍ឯក សួង ឡោត អត្តលេខ ០៤១៦៨៧
៧៣-អនុសេនីយ៍ឯក សិ ម៉ុនហៀក អត្តលេខ ០១៩១៦៥
៧៤-អនុសេនីយ៍ឯក យន្ត សាមាន អត្តលេខ ០៤១៧១២
៧៥-អនុសេនីយ៍ឯក ជា ឡឿន អត្តលេខ ០២៩៦៧៤
៧៦-អនុសេនីយ៍ឯក សោម ផន អត្តលេខ ០២៩៦៣៥
៧៧-អនុសេនីយ៍ឯក ញ៉ា សារ៉ែន អត្តលេខ ០២៩៦៩៤
៧៨-អនុសេនីយ៍ឯក ប៉ាត នី អត្តលេខ ០១៩១៦២
៧៩-អនុសេនីយ៍ឯក សម អេម អត្តលេខ ០៤១៧០៨
៨០-អនុសេនីយ៍ឯក គៀម រឿម អត្តលេខ ០២៩៦៩៦

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៨១-អនុសេនីយ៍ឯក **ទុំ ជី** អត្តលេខ ០២៩៧១១
៨២-អនុសេនីយ៍ឯក **កែវ ដារ៉ា** អត្តលេខ ០២៩៦៧៥
៨៣-អនុសេនីយ៍ឯក **អឿ តាំ** អត្តលេខ ០១៩១៥២
៨៤-អនុសេនីយ៍ឯក **ម៉ិល ឆា** អត្តលេខ ០២៩៧៤៥
៨៥-អនុសេនីយ៍ឯក **ផល សុជាតិ** អត្តលេខ ០២៩៧២៥
៨៦-អនុសេនីយ៍ឯក **ផាប់ តឿន** អត្តលេខ ០១៩១៥៧
៨៧-អនុសេនីយ៍ឯក **សួន សូត្រ** អត្តលេខ ០១៩១៦៩
៨៨-អនុសេនីយ៍ឯក **ស៊ឹម បូណា** អត្តលេខ ០១៩១៧០
៨៩-អនុសេនីយ៍ឯក **តែ សុខហាក់** អត្តលេខ ១៥៦៩៣៩
៩០-អនុសេនីយ៍ឯក **អ៊ុខ សុខា** អត្តលេខ ១៥៦៩៣៦
៩១-អនុសេនីយ៍ឯក **សុខ ឧត្តី** អត្តលេខ ០៤១៧៥១
៩២-អនុសេនីយ៍ឯក **ហៃ ស៊ីត** អត្តលេខ ០៤១៧៥៦
៩៣-អនុសេនីយ៍ឯក **មឿន វៃ** អត្តលេខ ០១៩៤៤០
៩៤-អនុសេនីយ៍ឯក **រុំ សារៀម** អត្តលេខ ០៤១៧៥៣
៩៥-អនុសេនីយ៍ឯក **ម៉ែន សាឌុន** អត្តលេខ ០៤១៧៣២
៩៦-អនុសេនីយ៍ឯក **លន់ គឿន** អត្តលេខ ០៣៩៤២១
៩៧-អនុសេនីយ៍ឯក **ស្វាយ សារ៉ែន** អត្តលេខ ០២៩៧៤១
៩៨-អនុសេនីយ៍ឯក **តី សុភាព** អត្តលេខ ០២៩៧៣៩
៩៩-អនុសេនីយ៍ឯក **ឡាយ ឡុខ** អត្តលេខ ០២៩៧៤៩
១០០-អនុសេនីយ៍ឯក **អ៊ុំ សារ៉ែន** អត្តលេខ ០២៩៧៣៤
១០១-អនុសេនីយ៍ឯក **យ៉ាំង សារឿន** អត្តលេខ ១៥៦៩៤៣
១០២-អនុសេនីយ៍ឯក **សៅ ឧត្តម** អត្តលេខ ០២៩៦៧៦
១០៣-អនុសេនីយ៍ឯក **សាយ ម៉ៅ** អត្តលេខ ០៦៤៧៧២
១០៤-អនុសេនីយ៍ឯក **តិច ប៊ុនលី** អត្តលេខ ០២៩៧២៧
១០៥-អនុសេនីយ៍ឯក **ឡាយ ចិក** អត្តលេខ ១៥៦៩៩៨
១០៦-អនុសេនីយ៍ឯក **យ៉ាន សុភាព** អត្តលេខ ០២៩៧៣៨
១០៧-អនុសេនីយ៍ឯក **សឿន គេច** អត្តលេខ ១០៣៥៤៤
១០៨-អនុសេនីយ៍ឯក **មេឃ ឌួន** អត្តលេខ ០១០០៥០
១០៩-អនុសេនីយ៍ឯក **ហែម ចំរើន** អត្តលេខ ០៤១៧៣១
១១០-អនុសេនីយ៍ឯក **សោម សារ៉ាន** អត្តលេខ ០១៩២០៥
១១១-អនុសេនីយ៍ឯក **ថន អៀប** អត្តលេខ ០៤១៧៤៥
១១២-អនុសេនីយ៍ឯក **ប៉ុល ឌុច** អត្តលេខ ០២៩៧៣១
១១៣-អនុសេនីយ៍ឯក **ហ្វូន ភន** អត្តលេខ ០១៩១៥៩
១១៤-អនុសេនីយ៍ឯក **ប៊ុន ម៉េង** អត្តលេខ ០៤១៧៤៦
១១៥-អនុសេនីយ៍ឯក **ឈន់ គុណា** អត្តលេខ ០២៩៧៤២
១១៦-អនុសេនីយ៍ឯក **ឈុន លីមប៊ិច** អត្តលេខ ០៤១៧៤៤
១១៧-អនុសេនីយ៍ឯក **ហ៊ាន់ ហ៊ាត់** អត្តលេខ ០៤១៧៤៩
១១៨-អនុសេនីយ៍ឯក **យ៉េន យ៉ាំង** អត្តលេខ ០២៩៧២៦
១១៩-អនុសេនីយ៍ឯក **អន ចាន់ណា** អត្តលេខ ១៥៤៤៣៣
១២០-អនុសេនីយ៍ឯក **អេច ណុល** អត្តលេខ ១៥៦៩៣៥
១២១-អនុសេនីយ៍ឯក **នុត មុន្នី** អត្តលេខ ០១២៣០៦
១២២-អនុសេនីយ៍ឯក **ស៊ឹម រិទ្ធ** អត្តលេខ ០៩១៣៤៧

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

១២៣-អនុសេនីយ៍ឯក**ងុច ឆារី** អត្តលេខ ០២៩៦៩១
១២៤-អនុសេនីយ៍ឯក **កែវ ឡុម** អត្តលេខ ០៣៣៨៤៥
១២៥-អនុសេនីយ៍ឯក **សោមសារុង** អត្តលេខ ០៦៤៧៨៣
១២៦-អនុសេនីយ៍ឯក **អួន យ៉ន** អត្តលេខ ០៤១៧៤២
១២៧-អនុសេនីយ៍ឯក**សេង មុត** អត្តលេខ ០៧៣១៨៩
១២៨-អនុសេនីយ៍ឯក **នុត គ្រោម** អត្តលេខ ១៤៦៦៧៤
១២៩-អនុសេនីយ៍ឯក **ជា ណារាជ** អត្តលេខ ០៥២៨១៣
១៣០-អនុសេនីយ៍ឯក**វត្ត សិលា** អត្តលេខ ០៤៣៨៨៣
១៣១-អនុសេនីយ៍ឯក**ទ៉ាន សំរេច** អត្តលេខ ០៦៩៦១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៦៧១ ច.ល

៣.វ.ល. ១០០៩.៧០១

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**សូមឡាយព្រះហស្តលេខា**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១០
**នាយករដ្ឋមន្ត្រី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំង :

| | |
|---|---|
| ១- **ឯកឧត្តម ស្រី សៀង** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។ |
| ២- **ឯកឧត្តម គឹម គឹមសៀង** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ រដ្ឋលេខាធិការ ។ |

**មាត្រា២** : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១០០៨.៧០៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១០*

លេខៈ ៦៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ថុនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ២៣.៣៧៩ លានរៀល ( ម្ភៃបីពាន់បីរយចិតសិបប្រាំបួនលានរៀលគត់ ) ពីជំពូក ០៩ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ ( ការទិញ ) ចំនួន ៩.៩២៤ លានរៀល មកជំពូក ៦៥ ( ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ៤.៦៩៦ លានរៀល របស់ក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ មកជំពូក ៦៥ ( ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ២.៩៣៨ លានរៀល របស់ក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ និង មកជំពូក ៦០ ( ការទិញ ) ចំនួន ៥.៨២១ លានរៀល របស់ក្រសួងការពារជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូន:

-ក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ ចំនួន ១៤.៦២០ លានរៀល ក្នុងនោះ : ទឹកប្រាក់ ចំនួន ៩.៩២៤ លានរៀល សម្រាប់ទូទាត់សងថ្លៃផ្គត់ផ្គង់ឯកសណ្ឋាន លក្ខណៈសញ្ញាសក្តិ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ ជូនកងកម្លាំងនគរបាលជាតិ ជូនក្រុមហ៊ុន **សោម សុផល** និងទឹកប្រាក់ ចំនួន ៤.៦៩៦ លានរៀល សម្រាប់ទូទាត់បំណុលផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនក្រុមហ៊ុន **ហ្គោលដែនឆៃណា** ។

-ក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ ចំនួន ២.៩៣៨ លានរៀល សម្រាប់ទូទាត់បំណុលផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនក្រុមហ៊ុន **ឈុន ហុង** ។

-ក្រសួងការពារជាតិ ចំនួន ៥.៨២១ លានរៀល សម្រាប់ទូទាត់បំណុលកិច្ចសន្យាទិញអង្ករដែលនៅសេសសល់ពីឆ្នាំ ២០០៣ ជូនក្រុមហ៊ុន **ម៉ែន សារុន** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៨ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២០.០០០ លានរៀល (ម្ភៃពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ៣.៥០០ លានរៀល និងមកជំពូក ៦៥ (ឧបត្ថម្ភធន និងជំនួយសង្គម) ចំនួន ១៦.៥០០ លានរៀល ជូនទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ដំណើរការប្រតិបត្តិ-ការការងារបន្តឆ្នាំ ២០១០ និងទូទាត់បុរេប្រទានខ្ទង់ចំណាយពិសេសឆ្នាំ ២០១០។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦, ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៧ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ១២៦០ សហវ.ប្រក, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- យោងលិខិតលេខ ៥៩៤ សនថហ, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ របស់ក្រសួងសុខាភិបាល

**មាត្រា ១**: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាមិនមែនកម្មវិធីចំនួនៈ ៨៣៣.០០០.០០០ រៀល (ប្រាំបីរយសាមសិបបីលានរៀលគត់) ចេញពីជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងសុខាភិបាល ដើម្បីបំពេញតម្រូវការចំណាយចាំបាច់ក្នុងការដឹកជញ្ជូនឱសថ ប្រតិករ ពីកំពង់ផែ ព្រលានយន្តហោះមកឃ្លាំងឱសថកណ្តាលក្នុងឆមាសទី២ ឆ្នាំ ២០១០ ។

**មាត្រា២**:ការបែងចែកឥណទានចំណាយថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងសុខាភិបាលសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១០។

**មាត្រា ៣**:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**អ៊ុក រ៉ាប៊ុន**
**រដ្ឋមន្ត្រីស្តីទីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០៧. អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម /០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ដែលសរសេរអក្សរកាត់ថា **គ.ជ.ប.ស.** ។

គ.ជ.ប.ស. ជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាបរិស្ថានដែលប៉ះពាល់ដល់សុខភាពសាធារណៈ ។

## ជំពូកទី២

### សមាសភាពរបស់ គ.ជ.ប.ស.

**មាត្រា២._**

គ.ជ.ប.ស. មានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| -រដ្ឋមន្ត្រី | ក្រសួងសុខាភិបាល | | ប្រធាន |
| -រដ្ឋលេខាធិការ | ក្រសួងបរិស្ថាន | ១រូប | អនុប្រធាន |
| -រដ្ឋលេខាធិការ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | អនុប្រធាន |
| -រដ្ឋលេខាធិការ | ក្រសួងសុខាភិបាល | ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -រដ្ឋលេខាធិការ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងការពារជាតិ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងផែនការ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១រូប | សមាជិក |

-រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងធនធានទឹក និង ឧតុនិយម ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងធម្មការ និង កិច្ចការសាសនា ១រូប សមាជិក

-អគ្គលេខាធិការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក។

សមាសភាពជាក់ស្តែងរបស់ **គ.ជ.ប.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## ភារកិច្ចរបស់ គ.ជ.ប.ស.

**មាត្រា៣.-**

**គ.ជ.ប.ស.** មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនៃបរិស្ថាន និងសុខភាព ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញ និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនៃបរិស្ថាន និងសុខភាព ដើម្បីលើកកម្ពស់ការការពារបរិស្ថាននិងសុខភាពរបស់ប្រជាពលរដ្ឋ ដែលជាកត្តាចម្បងក្នុងការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស វឌ្ឍនភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកប ដោយចីរភាព

- បង្កើនកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាស្ថាប័ននៅគ្រប់ថ្នាក់ គ្រប់ផ្នែក ជាពិសេសប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាសហគមន៍អន្តរជាតិលើវិស័យបរិស្ថាននិងសុខភាព
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ស្តីពីបរិស្ថាននិងសុខភាពជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ប.ស.

**មាត្រា៤.-**

សមាជិក **គ.ជ.ប.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**គ.ជ.ប.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

**មាត្រា៥.-**

**គ.ជ.ប.ស.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល ។

**គ.ជ.ប.ស.** អាចទទួលធនធានផ្គត់ផ្គង់ដោយមូលនិធិជាហិរញ្ញប្បទាន ដែលបានមកពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងៗសម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ។

**គ.ជ.ប.ស.** មានក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ។ សមាសភាពនិងតួនាទី ភារកិច្ចរបស់ក្រុមការងារបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ប.ស.** ។

**គ.ជ.ប.ស.** មាននាយកដ្ឋានការពារសុខភាពនៃក្រសួងសុខាភិបាលជាលេខាធិការដ្ឋាន ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិ/ហ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៧

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០៨ .អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥២អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៨៩អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណង ដូចតទៅ ៖

- ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងកម្មវិធីនយោបាយរាជរដ្ឋាភិបាលចំពោះជនពិការ
- ផ្តល់ឱកាសការងារ លើកទឹកចិត្តដល់ជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង ចូលបម្រើការងារ
- លើកកម្ពស់សេចក្តីថ្លៃថ្នូរ សុខុមាលភាព និងសិទ្ធិរបស់ជនពិការកម្ពុជាតាមរយៈការទទួលស្គាល់សមត្ថភាពជនពិការ ប្រសើរជាងការមើលឃើញតែពិការភាពរបស់ជនពិការ
- ចូលរួមបំពេញនូវកាតព្វកិច្ចរបស់កម្ពុជាជាហត្ថលេខីនៃអនុសញ្ញា និងកតិកាសញ្ញាដែលទាក់ទងសិទ្ធិមនុស្ស និងសិទ្ធិជនពិការ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានកាតព្វកិច្ចក្នុងការជ្រើសរើសជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ។

**មាត្រា៤.-**

**ការសម្របសម្រួលសមស្របមានបន្ទុកធ្ងន់ធ្ងរហួសហេតុ** សំដៅដល់ការសម្របសម្រួលលើប្រភេទ និងលក្ខខណ្ឌការងារ ការហ្វឹកហ្វឺន ផ្នែកបរិស្ថាន ទីកន្លែងការងារ មធ្យោបាយ សម្ភារបរិក្ខារ ដែលហួសពីលទ្ធភាពរបស់ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល។

## ជំពូកទី២
## ការកំណត់អត្រាជនពិការចូលបម្រើការងារ

**មាត្រា៥.-**

ក្រសួង ស្ថាប័នរដ្ឋ ដែលមានមន្ត្រីរាជការ ចាប់ពី ៥០ (ហាសិប) នាក់ឡើងទៅ ត្រូវតែមានជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារ ដូចកំណត់តាមមាត្រា១១នៃអនុក្រឹត្យនេះ ចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការក្នុងអត្រា២ (ពីរ) ភាគរយ នៃចំនួនមន្ត្រីរាជការសរុប។

ការកំណត់ចំនួនជនពិការឲ្យចូលបម្រើការងារក្នុងកងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៦.-**

នីតិបុគ្គល ដែលមានកម្មករ និយោជិត ចាប់ពី ១០០ (មួយរយ) នាក់ឡើងទៅ ត្រូវមានជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារ ដូចកំណត់តាមមាត្រា១១នៃអនុក្រឹត្យនេះ ក្នុងអត្រា ១ (មួយ) ភាគរយ នៃចំនួនកម្មករ និយោជិតសរុប។

**មាត្រា៧.-**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានមន្ត្រីរាជការ និងកម្មករ និយោជិតតិចជាងចំនួនដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ហើយបានជ្រើសរើសជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ ត្រូវទទួលបានការលើកទឹកចិត្តដូចមានចែងក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

វិធីសាស្ត្រនៃការគណនាជនពិការស្របតាមលក្ខណវិនិច្ឆ័យ ប្រភេទ និងកម្រិតនៃពិការភាពដូចកំណត់ក្នុងមាត្រា២០នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការត្រូវអនុវត្តដូចខាងក្រោម៖

| ប្រភេទការងារ | ប្រភេទពិការភាព | កម្រិតពិការភាព | គណនាចំនួន |
|---|---|---|---|
| មន្ត្រីរាជការ និយោជិត បម្រើការងារពេញម៉ោង | ជនពិការកាយសម្បទា | ធ្ងន់ | ជនពិការ១នាក់ត្រូវគិតជា២នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| | ជនពិការកាយសម្បទា | ស្រាល មធ្យម | ជនពិការ១នាក់ត្រូវគិតជា១នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| និយោជិត បម្រើការងាររយៈពេលខ្លី | ជនពិការកាយសម្បទា | ធ្ងន់ | ជនពិការ១នាក់ត្រូវគិតជា១នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| | ជនពិការកាយសម្បទា | ស្រាល មធ្យម | ជនពិការ១នាក់ត្រូវគិតជាកន្លះនាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |

## ជំពូកទី៣
## បែបបទជ្រើសរើស

**មាត្រា៩.-**

ក្រសួង ស្ថាប័នរដ្ឋ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ នៅក្នុងខែមករា ជារៀងរាល់ឆ្នាំ អំពី ៖

- ចំនួនមន្ត្រីរាជការសរុប លើកលែងកងកម្លាំងប្រដាប់អាវុធ
- ចំនួនជនពិការ ដែលគ្រោងនឹងជ្រើសរើស តាមអត្រាកំណត់
- ចំនួនមន្ត្រីរាជការជាជនពិការកាយសម្បទា កម្រិតស្រាល មធ្យម
- ចំនួនមន្ត្រីរាជការជាជនពិការកាយសម្បទា កម្រិតធ្ងន់
- ចំនួនមន្ត្រីរាជការជាជនពិការសតិបញ្ញា កម្រិតស្រាល មធ្យម
- ចំនួនមន្ត្រីរាជការជាជនពិការសតិបញ្ញា កម្រិតធ្ងន់។

ក្នុងករណី ក្រសួង ស្ថាប័នរដ្ឋ ទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ឲ្យជ្រើសរើសក្របខណ្ឌមន្ត្រីរាជការចូលធ្វើការងារ ត្រូវកសាងផែនការជ្រើសរើសជនពិការតាមអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៥ខាងលើ ផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាត ។

**មាត្រា១០.-**

នីតិបុគ្គល ដែលមានកម្មករ និយោជិត ចាប់ពី ១០០ (មួយរយ) នាក់ឡើងទៅ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាទៀងទាត់រៀងរាល់ឆ្នាំទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងខែមករា ជារៀងរាល់ឆ្នាំ អំពី ៖

- ចំនួនកម្មករ និយោជិត ធ្វើការពេញម៉ោង សរុប
- ចំនួនកម្មករ និយោជិតជាជនពិការ ដែលគ្រោងជ្រើសរើស តាមអត្រាកំណត់
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតស្រាល មធ្យម ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតធ្ងន់ ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតស្រាល មធ្យម ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតធ្ងន់ ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតស្រាល មធ្យម ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតធ្ងន់ ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតស្រាល មធ្យម ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតធ្ងន់ ធ្វើការរយៈពេលខ្លី ។

ក្នុងករណីដែលនីតិបុគ្គលជ្រើសរើសកម្មករ និយោជិត ជាជនពិការកាយសម្បទា ឬសតិបញ្ញា ចូលធ្វើការមិនទាន់គ្រប់ចំនួនតាមអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវកសាងផែនការជ្រើសរើសឡើងវិញ ផ្ញើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមុនដំណាច់ខែធ្នូនៃឆ្នាំ។

**មាត្រា១១.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ប្រភេទការងារ ដែលជនពិការអាចធ្វើបាន ផ្ញើជូនគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលមានកាតព្វកិច្ចជ្រើសរើសជនពិការចូលបម្រើការងារ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ ជាសាធារណៈ។

**មាត្រា១២.-**

កាលបរិច្ឆេទនៃការប្រឡងជ្រើសរើសណាមួយ ដែលអាចមានជនពិការកាយសម្បទា ឬសតិបញ្ញាដែលមានលក្ខណសម្បត្តិ និងសមត្ថភាព ឲ្យចូលក្នុងក្របខណ្ឌមន្ត្រីរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយយ៉ាងតិច ៣ (បី) ខែមុនថ្ងៃបើកឲ្យចូលប្រឡង។ ក្នុងករណីដែលមានការប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ។

ចំពោះការជ្រើសរើសចូលបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថាន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្សព្វផ្សាយយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ។

**មាត្រា១៣.-**

គ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមិនទាន់មានជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាព បំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងតាមអត្រាកំណត់ ដូចមានចែងក្នុង

មាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវកសាងផែនការប្រឡងជ្រើសរើសបំពេញបន្ថែម ឲ្យបានគ្រប់ចំនួនក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ។

ការកសាងផែនការជ្រើសរើសបំពេញបន្ថែម ត្រូវធ្វើជារៀងរាល់ឆ្នាំ។ ក្នុងមួយឆ្នាំៗ ត្រូវជ្រើសរើសឲ្យបានយ៉ាងតិច ៣០ (សាមសិប) ភាគរយ នៃគម្រោងផែនការជ្រើសរើសសរុបរយៈពេល ៣ (បី) ឆ្នាំ។

## ជំពូកទី៤
## ភាតព្វកិច្ច និងការសម្របសម្រួលសមស្រប

**មាត្រា១៤.–**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវមានកាតព្វកិច្ចធ្វើការសម្របសម្រួលសមស្រប សម្រាប់មន្ត្រីរាជការ កម្មករ និយោជិត ឬកូនជាង ឬកម្មសិក្សាការីជាជនពិការ ជាអាទិ៍ ការសម្របសម្រួលលើប្រភេទ និងលក្ខខណ្ឌការងារ ការហ្វឹកហ្វឺន ផ្នែកបរិស្ថាន ទីកន្លែងការងារ មធ្យោបាយ សម្ភារបរិក្ខារ លើកលែងតែ ការសម្របសម្រួលសមស្រប មានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

## ជំពូកទី៥
## ការបង់ភាគទាន ការលើកទឹកចិត្ត និងការពិន័យ

**មាត្រា១៥.–**

ប្រធានក្រសួង ស្ថាប័នរដ្ឋ ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ត្រូវបង់ភាគទានចូលហិបមូលនិធិជនពិការជាប្រាក់ស្មើនឹង៥០ (ហាសិប) ភាគរយ នៃប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការក្នុងមួយខែតាមប្រភេទក្របខណ្ឌ សម្រាប់មន្ត្រីរាជការជាជនពិការ ១ (មួយ) នាក់។

នីតិបុគ្គល ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបង់ភាគទានចូលហិបមូលនិធិជនពិការជាប្រាក់ស្មើនឹង ៤០ (សែសិប) ភាគរយ នៃប្រាក់បៀវត្សអប្បបរមាប្រចាំខែរបស់កម្មករ និយោជិត ក្នុងមួយខែ សម្រាប់កម្មករ និយោជិតជាជនពិការ ១ (មួយ) នាក់។

**មាត្រា១៦.–**

ការបង់ភាគទាន ដូចមានចែងក្នុងមាត្រា១៥ ខាងលើត្រូវអនុវត្តតាមនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ។

**មាត្រា១៧.–**

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលបានបំពេញកាតព្វកិច្ចលើសអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវទទួលបានការលើកសរសើរ និង/ឬការលើកទឹកចិត្ត [illegible]

តាមច្បាប់ជាធរមាន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ។

**មាត្រា១៨.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា១៥ នៃ អនុក្រឹត្យនេះ ហើយមិនព្រមបង់ភាគទានចូលហិបមូលនិធិជនពិការ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចមានចែងក្នុងមាត្រា៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

ក្នុងករណីមិនគោរពតាមកថាខណ្ឌខាងលើ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៥៦ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៩៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១:** តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម៖

១- លោកស្រី រស់ សុខាល

២- លោកស្រី ឈិន រួចម៉េង

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៨៩៨.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនអ្នកស្រី **SASAKI Atsuko** សប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកា ចំនួន ៣១.៣៦៥.៣០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ បង្គន់អនាម័យ មាន០៤បន្ទប់ និង អណ្តូងទឹក ០១ ជូនដល់សាលាបឋមសិក្សាអូរមាស ស្ថិតនៅឃុំពង្រលើ ស្រុកជីក្រែង ខេត្តសៀមរាប ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១០

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៦៩. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនលោក **SHIGETA YASUMITSU** ដែលបានផ្តល់ថវិកាចំនួន ៥៨.២៨៧ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ ធ្វើពីថ្មប្រក់ក្បឿង ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់វិទ្យាល័យក្តីទន្ទឹម ស្ថិតនៅក្នុងឃុំជើងគួន ស្រុកសំរោង ខេត្តតាកែវ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **SONODA YOSHIO** ដែលបានផ្តល់ថវិកាចំនួន ៥១.៥០០ ដុល្លារ តាមរយៈអង្គការ **School Aid Japan** ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន ០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សាព្រះអំពិល ស្ថិតនៅភូមិព្រះអំពិល ឃុំបឹងបត់កណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩០១ .អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **KITAHARA Takafumi** ប្រធានគណៈកម្មការអប់រំទីក្រុងសាប៉ូរ៉ូនៃប្រទេសជប៉ុន ដែលបានផ្តល់តុ-កៅអីសិស្សចំនួន ៤៧៦៤ សំរាប់ ជូនដល់សាលាបឋមសិក្សាមួយចំនួននៅខេត្តបាត់ដំបង ព្រៃវែង និងរាជធានីភ្នំពេញ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ព្រៃវែង និង រាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ១៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តអង្គព្រះស្តេច** ស្ថិតនៅក្នុងឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **ឌឹម សុគន់** ព្រះចៅអធិការវត្តអង្គព្រះស្តេច បច្ច័យចំនួន ២៧.៣៦៣ ដុល្លារ

២-ព្រះតេជគុណ **សំ ចាន់** ព្រះវិន័យធរវត្តឧណ្ណាលោម បច្ច័យចំនួន ២៣.៧៦០ ដុល្លារ

៣-លោក **អៀង ណៃ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៣.១៥០ ដុល្លារ

៤-លោក **ពេជ្រ វង្សសេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.១៦២ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

១-លោក **ដួង ហ៊ើល** ប្រធានគណៈកម្មការវត្តអង្គព្រះស្តេច ថវិកាចំនួន ៨.៥៥៧ ដុល្លារ

២-លោក **ពេជ្រ សេងតិន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៨.៥២០ ដុល្លារ

| | | | | |
|---|---|---|---|---|
| ៣-លោក | គង់ សុខ | អនុប្រធានគណៈកម្មការវត្តអង្គព្រះស្តេច | ថវិកាចំនួន ៧.៥៧០ ដុល្លារ |
| ៤-លោក | អ៊ុច សុខា | គណៈកម្មការកសាងវត្តអង្គព្រះស្តេច | ថវិកាចំនួន ៧.៥៥០ ដុល្លារ |
| ៥-លោក | ឡៀប ឡេង | មេឃុំបឹងត្រាញ់ខាងជើង | ថវិកាចំនួន ៧.១០០ ដុល្លារ |

**គ. មេដាយសុវត្ថារាជាតិចំនួន ០៥ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណធម្មធរោ អ៊ី អ៊ុ | គណៈកម្មការកសាងវត្តអង្គព្រះស្តេច | បច្ច័យចំនួន ៣.៥២០ ដុល្លារ |
| ២-ឧបាសក ប្រាក់ ឈាវ | អាចារ្យវត្តអង្គព្រះស្តេច | ថវិកាចំនួន ៤.១០០ ដុល្លារ |
| ៣-លោកស្រី រ័ត្ន ស្រី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៣.៧២០ ដុល្លារ |
| ៤-លោក ជួង ប៊ុន | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៣.៥៥០ ដុល្លារ |
| ៥-ឧបាសក ស អ៊ុក | គណៈកម្មការកសាងវត្តអង្គព្រះស្តេច | ថវិកាចំនួន ៣.១២០ ដុល្លារ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩០៣ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ ជូនលោកវេជ្ជបណ្ឌិត ក្លូត ឌុយមៀរសៀ ( Le docteur Claude Dumurgier ) ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជួយបណ្តុះបណ្តាល និងបញ្ជូននាយទាហាននិស្សិត វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល នៃកងយោធពលខេមរភូមិន្ទ ទៅសិក្សានៅប្រទេសបារាំង ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/ ...

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៩០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគកម្លាំងកាយចិត្ត និងធនធានផ្ទាល់ខ្លួន ជួយស្ថាបនាផ្លូវ និងទីធ្លាស្ថិតក្នុងទីបញ្ជាការដ្ឋាន កងពលតូចលេខ២១ ដូចមានរាយនាមខាងក្រោម៖

១- លោក **ស្រ៊ុន សំណាង** ប្រធានសភាមុខរបរ និងជាប្រធានក្រុមហ៊ុនកិនថ្ម
២- លោក **ទ៉ា សុគន្ធី** ជំនួយការឯកទេសផ្នែកវិស្វកម្ម

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០៥ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ប្រគេនព្រះមុនីកោសល **ហ៊ុល សុវណ្ណ** រាជាគណៈ ថ្នាក់ទោ ព្រះអនុគណខណ្ឌឫស្សីកែវ និងជាចៅអធិការវត្តទួលសុវណ្ណារាម ដែលបានបរិច្ចាគបច្ច័យចំនួន ៣.០០០ ដុល្លារ ក្នុងការជួយសាងសង់បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាទួលសង្កែ ស្ថិតនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩០៦ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហានសង្កេតការណ៍យោធារក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ នៅប្រទេសស៊ូដង់ ចំនួន០៥រូប ដូចមានរាយនាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ឯក | គាត់ | ប៊ើន | អត្តលេខ ០០១៩០៩ | នាយទាហានសង្កេតការណ៍យោធា |
| ២-វរសេនីយ៍ទោ | គង់ | មរកត | អត្តលេខ ០០៤២២៣ | នាយទាហានសង្កេតការណ៍យោធា |
| ៣-វរសេនីយ៍ទោ | ប្រាក់ | សារិន | អត្តលេខ ០០៩១៣៦ | នាយទាហានសង្កេតការណ៍យោធា |
| ៤-វរសេនីយ៍ទោ | កែវ | ម៉ាណា | អត្តលេខ ០០៨៧៣៨ | នាយទាហានសង្កេតការណ៍យោធា |
| ៥-វរសេនីយ៍ត្រី | អ៊ុំ | សុគន្ធី | អត្តលេខ ០៤៧០៥៧ | នាយទាហានសង្កេតការណ៍យោធា |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចំនួន២៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ:**

| | | | |
|---|---|---|---|
| ១-លោកវេជ្ជបណ្ឌិត | រស់ | សីលវ៉ាត់ | អគ្គលេខាធិការរង |
| ២-លោកស្រីវេជ្ជ. | សៀង | សុរិយា | អគ្គលេខាធិការរង |
| ៣-លោក | ឌី | ចាន់ប៊ុនលឿ | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ |
| ៤-លោកស្រីវេជ្ជ. | ស៊ូ | សុភី | អនុប្រធាននាយកដ្ឋានផែនការត្រួតពិនិត្យវាយតំលៃនិងស្រាវជ្រាវ |
| ៥-លោកវេជ្ជ. | អ៊ឹង | យ៉ាណារ៉ាត | អនុប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន |
| ៦-លោកវេជ្ជ. | ឈា | សិទ្ធិ | អនុប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន |
| ៧-លោកវេជ្ជ. | លឹម | ភាល័យ | អនុប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យវាយតំលៃនិងស្រាវជ្រាវ |
| ៨-លោកវេជ្ជ. | លី | ចាន់វិរុធ | អនុប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យវាយតំលៃនិងស្រាវជ្រាវ |
| ៩-លោកស្រីវេជ្ជ. | ខាន់ | ចាន់មុនី | អនុប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ |
| ១០-លោកវេជ្ជ. | អ៊ុក | ម៉ារ៉ឌី | អនុប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ |

**ខ-មេដាយប្រាក់ការងារ:**

| | | | |
|---|---|---|---|
| ១-លោក | ឈុន | វ៉ាន់ធី | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ២-លោកវេជ្ជ. | តែ | ប៊ុនធូ | អនុប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន |

| | | |
|---|---|---|
| ៣-លោក | ហ៊ុន ស | ប្រធានការិយាល័យរដ្ឋបាល-របៀប |
| ៤-លោក | សោ សាវទន់ | ប្រធានការិយាល័យថវិកា ហិរញ្ញវត្ថុ |
| ៥-លោក | ស៊ឹម ពិចិត្រ | ប្រធានការិយាល័យគណនេយ្យ |
| ៦-លោក | ញៀម សុភត្រា | ប្រធានការិយាល័យផ្គត់ផ្គង់និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ |
| ៧-លោកស្រីវេជ្ជ. | ថោង ដាលីណា | ប្រធានការិយាល័យត្រួតពិនិត្យ វាយតំលៃ |
| ៨-លោកគ្រូពេទ្យ | ហួត សេរីរដ្ឋ | ប្រធានការិយាល័យបណ្តុះបណ្តាល |
| ៩-លោកវេជ្ជ. | ហេង ហៃ | ប្រធានការិយាល័យ ចលនាប្រភពធនធាន |
| ១០-លោក | ឆេង វណ្ណា | អនុប្រធានការិយាល័យគណនេយ្យ |
| ១១-លោកស្រី | ណារិទ្ធ មុនីរ័ត្ន | អនុប្រធានការិយាល័យ ថវិកា-ហិរញ្ញវត្ថុ |
| ១២-លោកស្រី | ស៊ុំ ដល្លា | អនុប្រធានការិយាល័យ បណ្តុះបណ្តាល |
| ១៣-លោកវេជ្ជ. | អ៊ឹង សុវណ្ណៈ | មន្ត្រីនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩០៨ អនក្រ.ធក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សម្រេច

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម **ចំនួន ១២៨ នាក់** ដែលមានស្នាដៃល្អ ក្នុងការបម្រើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក- មេដាយមាសការងារ មានចំនួន ៦៨ រូប :**

| | | | | |
|---|---|---|---|---|
| 1 | លោកស្រី | **ព្រឿង** | **សាវ៉ាត** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ |
| 2 | លោក | **អូត** | **ឆម** | ប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 3 | លោក | **ច្រាយ** | **ហុងអៃ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល |
| 4 | លោក | **ម៉ា** | **សុផុន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល |
| 5 | លោក | **ហៅ** | **អាន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 6 | លោក | **អប់** | **វ៉ាឌី** | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 7 | លោក | **ស្វ** | **ស្រីម៉ិច** | អនុប្រធាននាយកដ្ឋាននីតិកម្ម |
| 8 | លោក | **យូ** | **ម៉ាប់** | អនុប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ |
| 9 | លោក | **ទីវ** | **សុជិនឡើន** | អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |

| | | | | |
|---|---|---|---|---|
| 10 | លោក | ខូន | សុមល្លីខង្សី | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 11 | លោក | ឃិន | មុន្នី | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 12 | លោក | ទុំ | ឈុនសេង | អនុប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 13 | លោក | ឥម | សុគី | អនុប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 14 | លោកស្រី | សុទ្ធ | សិរីវិចិត្រ | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តកែប |
| 15 | លោកស្រី | ខាត់ | រតនា | អនុប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 16 | លោក | សម | សុធា | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តរតនគិរី |
| 17 | លោក | ប្រាក់ | លន់ | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តតាកែវ |
| 18 | លោក | ហ៊ុំ | សុផាត | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តតាកែវ |
| 19 | លោក | តូច | សោភ័ណ្ឌ | ប្រធានការិយាល័យ នៃនាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ |
| 20 | លោក | សែស | សុធីរ | ប្រធានការិយាល័យ នៃនាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម |
| 21 | លោក | គួច | អានហ្វូត | ប្រធានការិយាល័យ នៃអគ្គាធិការដ្ឋាន |
| 22 | លោក | កែប | ខុន្ថា | ប្រធានការិយាល័យ នៃនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 23 | លោក | សំ | បូរី | ប្រធានការិយាល័យ នៃនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 24 | លោក | អឿន | សុភាព | ប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 25 | លោក | សុខ | សុគន្ធ | ប្រធានការិយាល័យ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 26 | លោក | ស៊ូ | ម៉ិច | ប្រធានការិយាល័យ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 27 | លោក | ឃឹម | រ័ត្ន | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 28 | លោក | ឈុន | ណារ៉ា | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 29 | លោក | លិ | ខុន្ថា | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 30 | លោក | ព្រៅ | ខេមរិទ្ធ | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 31 | លោក | អូច | សុខន | ប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មពហុភាគី |
| 32 | លោកស្រី | អ៊ាន | ធានី | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 33 | លោកស្រី | ជា | សុផ | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 34 | លោកស្រី | ឥម | យូរី | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម |
| 35 | លោក | ថៃ | យូអេង | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម |
| 36 | លោក | ហេង | ជា | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម |
| 37 | លោក | ញ៉ិប | ញ៉ឹម | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ |

| | | | | |
|---|---|---|---|---|
| 38 | លោក | សែត | ខចិត្រ | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន |
| 39 | លោក | តោ | ប៊ុនលី | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ |
| 40 | លោកស្រី | អ៊ុំ | ខុន្ធារិទ្ធ | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្គ្រីនត្រេដ |
| 41 | លោក | សាត | សុគន្ធ | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្គ្រីនត្រេដ |
| 42 | លោក | ថាច់ | ម៉ារីយ៉ា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម |
| 43 | លោក | សេខ | ខុន្ថា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម |
| 44 | លោក | ម៉ី | ប៊ុនលី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 45 | លោក | អៀ | អ៊ីរិទ្ធី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 46 | លោក | ម៉ែន | ការ៉េត | អនុប្រធានការិយាល័យ នៃនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 47 | លោក | គុជ | សុធា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 48 | លោក | សុខ | ចំរើន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ |
| 49 | លោក | ហ្មួយ | គឿន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 50 | លោក | ពេញ | ធារម្យ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 51 | លោកស្រី | ឡឹក | ស៊ីផន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| 52 | លោកស្រី | ឡាយ | ចាន់ធឿន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| 53 | លោក | អ៊ឹង | ដាមុនី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មពហុភាគី |
| 54 | លោក | ហោង | រ័ត្នខុន្ថា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មពហុភាគី |
| 55 | លោក | ជា | ចាន់ធី | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល |
| 56 | លោក | សៀង | ឥមជៀង | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប |
| 57 | លោក | ម្លេក | ចាវ | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប |
| 58 | លោក | ហ៊ិន | ហោង | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប |
| 59 | លោកស្រី | ជា | ឥមលី | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 60 | លោក | ឈុក | ប្រញ៉ាប់ | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 61 | លោកស្រី | អ៊ូ | ចន្ថា | មន្ត្រីនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 62 | លោក | ត្រាំ | ឈុនមិន | មន្ត្រី នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 63 | លោក | យ៉ាន | ប៉ាក់ | មន្ត្រីក្រុមហ៊ុនហ្គ្រីនត្រេដ |
| 64 | លោក | ស៊ី | ស៊ីវណ្ណា | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ |
| 65 | លោក | នៃន | ស៊ីធួន | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង |

ខ-មេដាយប្រាក់ការងារ មានចំនួន ៨៣ រូប ៖

| | | | | |
|---|---|---|---|---|
| 1 | លោក | សំរិទ្ធ | សាគូរ៉ា | អនុប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ |
| 2 | លោកស្រី | ធា | ម៉ារ៉ាវ | អនុប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម |
| 3 | លោកស្រី | អ៊ីង | វណ្ណារី | អនុប្រធាននាយកដ្ឋានរដ្ឋបាល |
| 4 | លោក | ហែម | សាម៉ុល | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម |
| 5 | លោក | ឡៅ | រាសី | ប្រធានការិយាល័យ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 6 | លោក | អ៊ុន | ចាន់ថា | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 7 | លោក | ម៉ែន | ចំរើន | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 8 | លោក | នួន | សុផល | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 9 | លោក | ខ៊ាន់ | កេង | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 10 | លោក | មួន | ចាន់ហៀក | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 11 | លោក | ឆេង | ប៊ុនថា | ប្រធានការិយាល័យគណនេយ្យហិរញ្ញវត្ថុ |
| 12 | លោក | យុន | ឧស្សាហ៍ | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 13 | លោក | ផុន | លីសក្កា | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 14 | លោក | ហេង | ណារ | ប្រធានសាខា នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 15 | លោក | ឃឹម | វ៉ុស្សាត | ប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មពហុភាគី |
| 16 | លោក | ឃឹម | សុផល | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្គ្រីនជ្រែត |
| 17 | លោកស្រី | សានី | តីនី | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្គ្រីនជ្រែត |
| 18 | លោក | ម៉ៅ | ចំរើន | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្គ្រីនជ្រែត |
| 19 | លោក | សំម | ស៊ីថាត | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ |
| 20 | លោក | ខាន់ | ចាន់ឧត្តិ | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពត |
| 21 | លោក | រ័ត្ន | សុខាល័យ | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ |
| 22 | លោក | សេក | ស៊ីធួន | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល |
| 23 | លោក | ហេង | សារឿន | អនុប្រធានការិយាល័យ នៃក្រុមហ៊ុនហ្គ្រីនជ្រែត |
| 24 | លោក | សៀង | ហុង | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 25 | លោកស្រី | ចាប | សុភាព | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 26 | លោកស្រី | យ៉ែម | សុគន្ធាវ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា |

| | | | | |
|---|---|---|---|---|
| 27 | លោក | គ្រឿង | សុផាត | អនុប្រធានការិយាល័យ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 28 | លោក | ម៉ុល | ចាន់ថា | អនុ.ការិយាល័យ នៃនាយកដ្ឋានស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម |
| 29 | លោក | ខាត់ | ចិន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 30 | លោក | ស្វាយ | សុផល | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 31 | លោក | ជិន | ស៊ាង | អនុប្រធានការិយាល័យ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 32 | កញ្ញា | សោម | ចិន្តា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 33 | លោក | ផេង | ឆេង | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 34 | លោក | ខៀវ | បញ្ញាវឌ្ឍន៍ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 35 | លោក | ចាប | យ៉ាវឿន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 36 | លោក | ទេព | ជាវ៉ូន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 37 | លោក | តែ | អ៊ុតឈាង | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 38 | លោក | ចេង | សុធ្ធារី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 39 | លោក | ជា | នី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 40 | លោក | ឯក | សារុន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 41 | លោក | នាយ | រដ្ឋ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 42 | លោក | នាយ | ផលរ័ត្ន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 43 | លោកស្រី | សូស | ផល្លា | អនុប្រធានសាខា នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 44 | លោក | ប៊ុន | សុខុមា | អនុប្រធានសាខា នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 45 | លោក | គន់ | យីហេង | អនុប្រធានសាខា នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 46 | លោក | ហេង | ម៉ាលី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 47 | លោក | ប៊ុន | សុភ័ក្ដ្ររិទ្ធ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 48 | លោក | ម៉េង | សុខជា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 49 | លោក | ប៊ុន | ចំរើន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 50 | លោក | ស៊ាន | ស៊ីណាត | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 51 | លោក | ឈុន | ឃាង | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 52 | លោក | ពៅ | ប៊ូផា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 53 | លោក | យ៉ាន់ | ចាន់ផល | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 54 | លោក | ជីម | ឧត្តរ៉ូ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |

| | | | | |
|---|---|---|---|---|
| 55 | លោក | ប៊ុន | សារម៉េត | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 56 | លោក | ទី | រ៉ូនី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 57 | លោក | ពេជ្រ | តារាម្សៀ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 58 | លោក | សៀ្វង | សុផេន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 59 | លោក | សេង | សុផល្លី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មពហុភាគី |
| 60 | លោកស្រី | នួន | សុខយ៉ាន | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 61 | លោក | ម៉ៅ | ឥទ្ធិ | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 62 | លោកស្រី | លី | ដាណារឿន | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពត |
| 63 | លោក | ហោ | ឡុង | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង |
| 64 | លោក | កង | ប៉ា | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ |
| 65 | លោក | អ៊ុន | សំអឿន | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង |
| 66 | លោក | សោម | រិន | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង |
| 67 | លោក | ឡាច | សារី | មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 68 | កញ្ញា | ឈុក | រដ្ឋ | មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 69 | លោក | ប៉ុល | ឥមសាន | មន្ត្រីនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 70 | លោកស្រី | សារីម | ពន្យសេដ្ឋា | មន្ត្រីនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 71 | លោក | ឯក | ឥមឈីន | មន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 72 | លោក | លី | គីមសាន | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 73 | លោក | កុក | លៀង | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 74 | លោក | ជ័យ | សារឿន | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 75 | លោក | ប៉ុក | ចណ្ណធាត | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 76 | លោក | នួន | ធឿន | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 77 | លោកស្រី | សុខ | ណារិន | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 78 | លោក | ឥម | សុខុម | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 79 | កញ្ញា | បុត្រ | ត័ក្រុសត្យា | មន្ត្រី នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 80 | លោក | ហ៊ីង | ម៉ាន់ដន | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកំពត |
| 81 | លោក | គួច | យិតឡាយ | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកំពត |
| 82 | លោកស្រី | ស្រី | យ៉េត | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប |

| | | | | |
|---|---|---|---|---|
| 83 | លោកស្រី | ឆាម | ផល្លី | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប |

គ-មេដាយសំរិទ្ធ ការងារ មានចំនួន ៧០ រូប ៖

| | | | | |
|---|---|---|---|---|
| 1 | លោក | ហ៊ុយ | រិទ្ធី | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 2 | លោក | មាន | ចំណាប់ | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 3 | លោក | ឈឹម | ចបុល | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 4 | លោក | គុណា | ប៊ុនថា | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 5 | លោក | ឈាន់ | ឡុងឌី | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 6 | លោកស្រី | ឃឹម | សំអាត | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 7 | លោកស្រី | រស់ | សារឿន | ប្រធានការិយាល័យ នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 8 | លោក | ធីម | ទ៉ា | ប្រធានការិយាល័យមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ |
| 9 | លោក | ហួត | ថា | ប្រធានការិយាល័យមន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង |
| 10 | លោក | ជូ | ឡានី | ប្រធានការិយាល័យមន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង |
| 11 | លោកស្រី | ឡឹង | ចាន់សុតា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 12 | លោកស្រី | ទ៉ា | ឥមឈាង | អនុប្រធានការិយាល័យ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 13 | លោក | សោម | ម៉ារីន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| 14 | លោកស្រី | ធុក | កេតថាវ៍ | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 15 | លោក | លាង | ស្រ៊ុន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 16 | លោក | ស៊ឹម | សុផារី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 17 | លោក | ង៉ែត | ត្រស្នា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 18 | លោកស្រី | យស | សុខា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 19 | លោក | សុន | សុវណ្ណា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 20 | លោក | ខេង | ប៊ុនថា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 21 | លោក | គន | ធី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 22 | លោក | ហ៊ិន | ង៉ែត | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 23 | លោក | ឡាំង | ចាន់សុវណ្ណា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 24 | លោក | ឃុត | មករា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 25 | លោក | ហុង | លៀង | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 26 | លោក | ឃុត | អ័ក្ខរ៉ា | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |

| | | | | |
|---|---|---|---|---|
| 27 | លោក | ដួង | មុនី | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 28 | លោក | ផង់ | ប៊ុនធឿន | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 29 | លោក | ឈួន | ចណ្ណាច័ន្ទចំណាន | អនុប្រធានការិយាល័យ នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 30 | លោក | គង់ | សុផុន | អនុប្រធានការិយាល័យមន្ទីរពាណិជ្ជកម្មខេត្តកោះកុង |
| 31 | លោកស្រី | ប៉ែត | ពុទ្ធចន្នី | អនុប្រធានការិយាល័យមន្ទីរពាណិជ្ជកម្មខេត្តតាកែវ |
| 32 | លោក | ផុន | ឡេងខ | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 33 | លោក | ប៊ុន | សម្បត្តិ | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| 34 | លោក | ស៊ាន | ស៊ីម៉េត | មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 35 | លោក | និត្យ | សាខឿន | មន្ត្រីនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 36 | លោក | យាន | យ៉ុង | មន្ត្រីនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 37 | កញ្ញា | មួយ | ជាអ៊ុន | មន្ត្រីអគ្គាធិការដ្ឋាន |
| 38 | លោក | ជា | ខរៈ | មន្ត្រីនាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 39 | លោក | ចោង | ម៉ៅ | មន្ត្រីនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 40 | លោក | អេង | ខឿន | មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| 41 | លោក | ឈោន | ឈោត | មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| 42 | លោក | សោម | សឿង | មន្ត្រីនាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ |
| 43 | លោក | គួយ | សៀវភលីម | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 44 | លោក | ឆាយ | ថូនី | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 45 | លោក | ប៉ែន | ធី | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 46 | លោក | គោត | គរុន | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 47 | លោក | ឡុង | កុល | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 48 | លោកស្រី | អ៊ុក | អាំរ៉ា | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 49 | លោក | អ៊ុត | សុឃិន | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 50 | លោក | សរ | សុវណ្ណសំបូរ | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 51 | លោកស្រី | ឡេង | ម៉ូនីកា | មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល |
| 52 | លោក | ឡុង | កែមវចិត្រ | មន្ត្រីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 53 | លោក | ឈី | កុលមុន្រា | មន្ត្រីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 54 | លោកស្រី | ឃិន | ស៊ីថា | មន្ត្រីក្រុមហ៊ុនហ្វ្រីនជ្រេត |

| | | | | |
|---|---|---|---|---|
| 55 | លោក | ចិន | អុល | មន្ត្រីក្រុមហ៊ុនហ្គ្រីនត្រេដ |
| 56 | លោក | ញ៉ៃ | សារឿន | មន្ត្រីក្រុមហ៊ុនហ្គ្រីនត្រេដ |
| 57 | លោក | ឈៀង | សន្ដរោ | មន្ត្រីក្រុមហ៊ុនហ្គ្រីនត្រេដ |
| 58 | លោកស្រី | ហេម | សុជាត | មន្ត្រីក្រុមហ៊ុនហ្គ្រីនត្រេដ |
| 59 | លោកស្រី | តាន់ | សុគន្ធ | មន្ត្រីក្រុមហ៊ុនហ្គ្រីនត្រេដ |
| 60 | កញ្ញា | ឈាង | ឡាពី | មន្ត្រីមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 61 | លោក | អៀង | ស៊ីវ៉ែន | មន្ត្រីមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 62 | លោក | កែប | បុណ្ណាវឌ្ឍ | មន្ត្រីមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 63 | លោក | ឥម | ឈាង | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកំពត |
| 64 | លោក | ហេង | វណ្ណៈ | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ |
| 65 | លោកស្រី | គត | ប៊ុននី | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកណ្ដាល |
| 66 | លោក | គូ | ឥមសាយ | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ |
| 67 | លោក | មេឈ | ចំណាន | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង |
| 68 | លោកស្រី | ឈូក | វណ្ណាស៊ី | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង |
| 69 | លោក | កាយ | ប៊ុនធី | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង |
| 70 | លោក | ឌិប | ជឿន | មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមានក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩០៩ . អនក្រ . បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម **ចំនួន ៧៨ នាក់** ដែលមានស្នាដៃល្អ ក្នុងការបម្រើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ មានចំនួន ១២ រូប :**

| | | | | |
|---|---|---|---|---|
| 1 | លោក | **មុី** | **សាម៉ន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ |
| 2 | លោក | **ស៊ឹម** | **អ៊ា** | អគ្គនាយករងពាណិជ្ជកម្មក្នុងប្រទេស |
| 3 | លោក | **ដួង** | **សុខ** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| 4 | លោក | **តូច** | **ចំនួនកេសី** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 5 | លោក | **ឱន** | **ឌ៉ានី** | អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 6 | លោក | **គ្រៃ** | **ស៊ីនហៀង** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 7 | លោក | **តាន់** | **សុខឡា** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 8 | លោក | **ទោច** | **ធីណា** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ |
| 9 | លោក | **ទៀង** | **ទៀន** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពត |

| | | | | |
|---|---|---|---|---|
| 10 | លោក | ហ៊ី | ណារត | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង |
| 11 | លោក | ប៊្រាល | ធីម | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពត |
| 12 | លោក | ជា | ស៊ីថា | ប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា មានចំនួន ២០ រូប :**

| | | | | |
|---|---|---|---|---|
| 1 | លោក | សុខ | សោផល | អគ្គាធិការស្តីទី |
| 2 | លោក | ម៉ិន | សុវណ្ណា | អគ្គាធិការរង |
| 3 | លោក | ស៊ុំ | ណារុន | អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 4 | លោក | ស៊ឹន | សុថា | ប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 5 | លោក | សាន | គរុណ្ណា | ប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 6 | លោក | ហុច | ម៉ុចហេច | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 7 | លោក | អ៊ុក | វណ្ណា | អនុប្រធាននាយកដ្ឋាននីតិកម្ម |
| 8 | លោក | ធិត | រិទ្ធិពល | ទីប្រឹក្សាពាណិជ្ជកម្មប្រចាំសហរដ្ឋអាមេរិក |
| 9 | លោក | យឹម | សុផល | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល |
| 10 | លោក | ស៊ាច | ម៉េចស្រ៊ាច | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម |
| 11 | លោក | សុខ | សេរី | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តមណ្ឌលគិរី |
| 12 | លោក | ដុំ | សំអឿន | ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ |
| 13 | លោក | ធែន | សារ៉ុម | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ |
| 14 | លោក | នច | សំហឿច | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង |
| 15 | លោក | ព្រំ | សំអុល | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តតាកែវ |
| 16 | លោក | ជិញ | សំភួ | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ |
| 17 | លោក | ស៊ឹន | សារ៉ាល់ | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តពោធិសាត់ |
| 18 | លោក | ឈួរ | ចាន់ថន | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង |
| 19 | លោក | ជាច | ឌុទ្ធី | ប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| 20 | លោក | ញៀម | ឥណារិទ្ធ | ប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |

**គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ មានចំនួន ៤៦ រូប :**

| | | | | |
|---|---|---|---|---|
| 1 | លោក | ម៉ក់ | ខុសភា | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 2 | លោក | សួន | សាន | ប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |

| | | | | |
|---|---|---|---|---|
| 3 | លោក | គង់ | សាខុន | អនុប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 4 | លោកស្រី | ចាន់ | សុខវ | អនុប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 5 | លោកស្រី | ទុច | សោភា | អនុប្រធាននាយកដ្ឋាន នៃក្រុមហ៊ុនហ្វ្រីនជ្រេត |
| 6 | លោកស្រី | កែវ | មុត្តធីតា | ទីប្រឹក្សាពាណិជ្ជកម្មប្រចាំក្រុងម៉ូស្គូ |
| 7 | លោក | សុខ | ជារិទ្ធិ | អនុប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| 8 | លោកស្រី | ម៉ិន | ឈារ៉ាត់ | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 9 | លោកស្រី | អ៊ាន់ | ធារី | អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម |
| 10 | លោក | ឡុង | សោភ័ណ | អនុប្រធាននាយកដ្ឋាននីតិកម្ម |
| 11 | លោក | ឈុប | សោភ័ណ្ឌតារ៉ា | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មពហុភាគី |
| 12 | លោក | សំ | សេរីឧត្តម | អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 13 | លោក | សេង | សៅ | ទីប្រឹក្សាពាណិជ្ជកម្មប្រចាំព្រះរាជាណាចក្រថៃ |
| 14 | លោក | ឌឹម | ថេង | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 15 | លោក | ឆេង | ម៉ានី | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកែប |
| 16 | លោក | ញ៉ឹល | សំប៊ូរ | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ |
| 17 | លោក | គូ | ឥមហ៊ត | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ |
| 18 | លោក | ស៊ុំ | ស៊ីណារ៉េន | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តក្រចេះ |
| 19 | លោកស្រី | យឹម | សាំងគាន | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តពោធិ៍សាត់ |
| 20 | លោក | លន់ | សាយលីន | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង |
| 21 | លោក | ជា | ជាន | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល |
| 22 | លោក | ជា | វណ្ណា | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង |
| 23 | លោក | ធឹង | ឥមហេង | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ |
| 24 | លោក | ជា | ម៉េង | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តក្រចេះ |
| 25 | លោកស្រី | ខៀវ | ម៉ានី | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តមណ្ឌលគិរី |
| 26 | លោក | អ៊ុន | អែម | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ |
| 27 | លោក | អ៊ាន់ | ហ៊ឿ | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តពោធិ៍សាត់ |
| 28 | លោក | សៀល | រីងកា | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តរតនគិរី |
| 29 | លោក | មន | ថេន | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប |

| | | | | |
|---|---|---|---|---|
| 30 | លោក | សុខ | សន្ធោ | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ |
| 31 | លោកស្រី | ហ៊ុយ | សៃណាល់ | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| 32 | លោក | គុយ | ផុក | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| 33 | លោក | ម៉ៅ | ធូ | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| 34 | លោក | អ៊ិន | ខឡូនា | ប្រធានការិយាល័យ នៃនាយកដ្ឋានផ្ដល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ |
| 35 | លោកស្រី | ចាយ | សារុំ | ប្រធានការិយាល័យ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| 36 | លោក | អ៊ឹម | ចំរុង | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 37 | លោក | ជុំ | សារ៉ាត់ | ប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| 38 | លោក | ចាន់ | ថាសនា | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកាំកុងត្រូល |
| 39 | លោក | ឃឹម | ម៉ុំ | ប្រធានការិយាល័យ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 40 | លោក | ទ៉ាន់ | ហួរ | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន |
| 41 | លោក | ឈឹម | សារិទ្ធ | ប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង |
| 42 | លោកស្រី | ខិន | ស៊ីផាត | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| 43 | លោក | ហ៊ុយ | សំអាត | អនុប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 44 | លោក | សៀ | យូ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម |
| 45 | លោក | ឃឹម | សំបូរ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី |
| 46 | លោក | គៀត | សារិន | អនុប្រធានការិយាល័យ មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមានក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៩៧០ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជម្រុញចលនា ភូមិ១ ផលិតផល ១

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៤រូប នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល ១ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ សេនា:**

១-លោកបណ្ឌិត លី ស៊ីណា អគ្គលេខាធិការរង
២-លោក អ៊ុច ចន្ថា អគ្គលេខាធិការរង
៣-លោក ពាំង ស៊ីផាត មន្ត្រី

**ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ:**

-ឯកឧត្តម ហាស់ ទង់ដារ៉ា អគ្គលេខាធិការរង

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជម្រុញចលនា ភូមិ១ ផលិតផល១ ត្រូវអនុវត្តអនុក្រឹត្យនេះ [illegible] ទទួលផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ៧ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩១១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាអធិការដ្ឋាន គណៈកម្មាធិការជាតិជម្រុញចលនា ភូមិ១ ផលិតផល ១

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៥រូប នៃអគ្គលេខាអធិការដ្ឋាន គណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល ១ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ:**

| | | | |
|---|---|---|---|
| ១-លោក | សុខ | សំអឿន | ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ |
| ២-លោក | ទៅ | សុទ្ធិ | ប្រធានផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| ៣-លោក | ភាំង | ច័ន្ទថា | មន្ត្រី |

**ខ-មេដាយប្រាក់ការងារ:**

| | | | |
|---|---|---|---|
| ១-លោក | តួច | សំណង់ | មន្ត្រី |
| ២-លោក | ច្រាក់ | សុជាតិ | មន្ត្រី |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធិភាព និងផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៩១៧ .អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និង សកម្មជន ចំនួន ២៣រូប ដែលបានខិតខំបំពេញ ភារកិច្ចទទួលបានជោគជ័យក្នុងការបោះឆ្នោតជាតិ អាណត្តិទី៤ និងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កន្លងមក ព្រមទាំងបានបរិច្ចាគធនធាន សម្ភារៈ ផ្ទាល់ខ្លួនក្នុងការរួមចំណែកអភិវឌ្ឍន៍នៅក្នុង ស្រុកកំពង់ត្របែក ខេត្តព្រៃវែងដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

| | | | |
|---|---|---|---|
| ១- | លោក | រិន ណារ៉ាន់ | ប្រធានមណ្ឌលផែទេសចរណ៍កំពង់ផែភ្នំពេញ |
| ២- | លោក | គុល សុខុម | អនុប្រធានសេវាដ្ឋាននាវាចរណ៍ និងកណ្តាលកំពង់ផែភ្នំពេញ |
| ៣- | លោក | ជា សោភ័ណ | នាយលេខាធិការដ្ឋានស្នងការដ្ឋានផែនការប្រតិបត្តិការ អ.ហ.ផ.ទ |
| ៤- | លោក | ប៊ិល ឆន | សមាជិកក្រុមប្រឹក្សាស្រុក កំពង់ត្របែក |
| ៥- | លោក | ប៊ូ សារូ | ប្រធានក្រុមប្រឹក្សាស្រុក កំពង់ត្របែក |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

| | | | |
|---|---|---|---|
| ១- | លោក | រស់ ចាន់ទាសនា | នាយកដ្ឋានបង្ក្រាបបទល្មើសសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ |
| ២- | លោកស្រី | សំរិទ្ធ សុខីភាព | នាយកដ្ឋានបង្ក្រាបបទល្មើសសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ |
| ៣- | លោកជំទាវ | ញ៉ឹម សាលី | ភរិយា ឯកឧត្តម មុំ ស៊ីប៊ុន |
| ៤- | លោកជំទាវ | ចាន់ ឡឿន | ភរិយា ឯកឧត្តម លីម ហោ |

៥- លោកជំទាវ ហ៊ុល ចន្ណារី ភរិយា ឯកឧត្តម ប៉ូលី ដា

៦- លោក ម៉ុម សុចិន្តា មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ

៧- លោក ប៉ែន កុសល ប្រធានការិយាល័យចុះបញ្ជីនាវាចរណ៍នាយកដ្ឋាននាវាចរណ៍សមុទ្រ

៨- លោក ខាន់ វ៉ាន់ អភិបាលនៃគណៈអភិបាលស្រុកកំពង់ត្របែក

៩- លោក ស្រី ឈុនលី អភិបាលរងនៃគណៈអភិបាលស្រុកកំពង់ត្របែក

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

១- អ្នកស្រី ហួត គីមយ៉េង សប្បុរសជន

២- លោក លឹម ធន់ សមាជិកក្រុមប្រឹក្សាស្រុកកំពង់ត្របែក

៣- លោក គីភ បូរី អភិបាលរងនៃគណៈអភិបាលស្រុកកំពង់ត្របែក

៤- លោក អ៊ុម សុមេធ ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុកកំពង់ត្របែក

៥- លោក ហាខ្យ គីមសាន ប្រធានការិយាល័យរៀបចំដែនដី នគររូបនីយកម្មសំណង់ និងភូមិបាលស្រុកកំពង់ត្របែក

៦- លោក យ៉ាទ សានិន ប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុកកំពង់ត្របែក

៧- លោក ជា សំណាង មេបញ្ជាការកងរាជអាវុធហត្ថស្រុកកំពង់ត្របែក

៨- លោក អ៊ុំ ចំរើន អធិការនគរបាលស្រុកកំពង់ត្របែក

៩- លោកស្រី ប៉ែន សុលក្ខិណា អនុប្រធានការិយាល័យធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩១៧ .អនក្រ.ធក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ និង សកម្មជន ចំនួន ៦៩រូប ដែលបានខិតខំបំពេញ ភារកិច្ចទទួលបានជោគជ័យក្នុងការបោះឆ្នោតជាតិ អាណត្តិទី៤ និងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កន្លងមក ព្រមទាំងបានបរិច្ចាគធនធាន សម្ភារៈ ផ្ទាល់ខ្លួនក្នុងការរួមចំណែកអភិវឌ្ឍន៍នៅក្នុង ស្រុកកំពង់ត្របែក ខេត្តព្រៃវែងដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោកស្រី | ម៉ៅ ចន្ថា | អភិបាលរងនៃគណៈអភិបាលស្រុកកំពង់ត្របែក |
| ២- | លោក | រដ្ឋ ច័ន្ទសីហារុន | ប្រធានមន្ទីរស្រុកកំពង់ត្របែក |
| ៣- | លោក | ម៉ុម សារ៉េត | មន្ត្រីគយ និងរដ្ឋាករច្រកទ្វារព្រំដែន |
| ៤- | លោក | ឆេព សម៉យ | អនុប្រធានការិយាល័យសុខាភិបាលស្រុកកំពង់ត្របែក |
| ៥- | លោក | ទ៉ូវ ភាព | ប្រធានមន្ទីរពេទ្យបង្អែកស្រុកកំពង់ត្របែក |
| ៦- | លោក | ប៉ិល សុធន | អនុប្រធានមន្ទីរពេទ្យបង្អែកស្រុកកំពង់ត្របែក |
| ៧- | លោក | អ៊ិន សំរេច | គណនេយ្យការិយាល័យសុខាភិបាលស្រុកកំពង់ត្របែក |
| ៨- | លោក | ថាត់ អូន | អនុប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុកកំពង់ត្របែក |
| ៩- | លោក | ពៅ តូ | អនុប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុកកំពង់ត្របែក |
| ១០- | លោក | ឈឹម សំអាន | អនុប្រធានស្នាក់ការពន្ធដារខេត្តព្រៃវែង |
| ១១- | លោក | សែន ចំណាន | មន្ត្រីទាយកដ្ឋានអង្គរក្សក្រសួងមហាផ្ទៃ |
| ១២- | លោក | ហុង ឡា | មន្ត្រីពន្ធដារខេត្ត |

| | | | | |
|---|---|---|---|---|
| ១៣- | លោក | ង៉ម | សុភាព | មន្ត្រីពន្ធដារខេត្ត |
| ១៤- | លោក | រស់ | ដារ៉ា | អនុប្រធានផែនការអគ្គនាយកដ្ឋានគយ និងរដ្ឋាករ |
| ១៥- | លោក | អ៊ិន | រស្មីឬទ្ធី | អនុប្រធានប៉ុស្តិ៍រដ្ឋបាលនគរបាលអាកាសយានដ្ឋានភ្នំពេញ |
| ១៦- | លោក | នួន | រតនា | អនុប្រធាននាយកដ្ឋានសរុបស្ថិតិអគ្គលេខាធិការក្រសួងមហាផ្ទៃ |
| ១៧- | លោក | មុត | ម៉ៅ | អនុប្រធានវិទ្យាស្ថានបណ្ឌិតសភានគរបាលកម្ពុជា |
| ១៨- | លោក | សូ | ម៉ុនធឿន | អនុប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម |
| ១៩- | លោក | ស៊ិន | ម៉ុនថន | ស្នងការរងហិរញ្ញវត្ថុអគ្គស្នងការនគរបាលជាតិ |
| ២០- | លោក | គង់ | ពុទ្ធី | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំអគ្គនាយកដ្ឋានភស្តុភារ |
| ២១- | លោក | ជា | សុភាព | អនុប្រធាននាយកដ្ឋាននគរបាលគាំទ្រការពារ |
| ២២- | លោក | ឃឹម | យោល | អនុប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ |
| ២៣- | លោក | អ៊ុយ | សារី | អនុប្រធាននាយកដ្ឋានបណ្ឌិតសភានគរបាលកម្ពុជា |
| ២៤- | លោក | ចាប | ចំណោ | នាយរងមន្ទីរប្រឆាំងគ្រឿងញៀន |
| ២៥- | លោក | ហឿង | សំអុល | អនុប្រធាននាយកដ្ឋានទេសចរណ៍ |
| ២៦- | លោក | ជា | យឿន | អនុប្រធាននាយកដ្ឋានបណ្ឌិតសភានគរបាលកម្ពុជា |
| ២៧- | លោក | សួន | វណ្ណា | អនុប្រធាននាយកដ្ឋានសរុបស្ថិតិអគ្គនាយកដ្ឋានក្រសួងមហាផ្ទៃ |
| ២៨- | លោក | ប៊ុះ | វ៉ាន់ | ជំនួយការបណ្ឌិតសភានគរបាលកម្ពុជា |
| ២៩- | លោក | សូ | សារ៉ាត់ | ជំនួយការបណ្ឌិតសភានគរបាលកម្ពុជា |
| ៣០- | លោក | រិត | សុខា | មន្ត្រីស្នងការនគរបាលរាជធានីភ្នំពេញ |
| ៣១- | លោក | ហេង | សារឿន | នាយកការិយាល័យគីមីសាស្ត្រអគ្គនាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រ |
| ៣២- | លោក | កែវ | ម៉ុនហួរ | មន្ត្រីលេខាធិការដ្ឋានអគ្គស្នងការនគរបាលជាតិ |
| ៣៣- | លោក | ហួត | ហាក់ | មន្ត្រីឧស្សាហកម្មខេត្តកណ្តាល |
| ៣៤- | លោក | សុខ | ពេជ្រ | មន្ត្រីនគរបាលនាយកដ្ឋានការពារ |
| ៣៥- | លោក | អ៊ឹម | ឌីយុទ្ធា | ប្រធានការិយាល័យផែនការស្រុក |
| ៣៦- | លោក | ប៊ូ | វាសនា | អនុប្រធានការិយាល័យសង្គមកិច្ចស្រុក |
| ៣៧- | លោក | ហៀង | សារុន | អនុប្រធានការិយាល័យកសិកម្មស្រុក |
| ៣៨- | លោក | ហ៊ិន | ឃឹម | មន្ត្រីការិយាល័យកសិកម្មស្រុក |
| ៣៩- | លោក | ជា | សុវណ្ណារ៉ា | អនុប្រធានមន្ទីរសាលាស្រុក |
| ៤០- | លោក | សូ | សុវណ្ណា | មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុក |
| ៤១- | លោកស្រី | ប៊ិល | សុធានី | មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុក |
| ៤២- | លោក | មាស | បូរី | មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុក |
| ៤៣- | លោក | មុំ | ទើន | សមាជិកក្រុមប្រឹក្សាឃុំចាម |
| ៤៤- | លោក | ស្រី | សំអាន | សមាជិកក្រុមប្រឹក្សាឃុំចាម |
| ៤៥- | លោក | រិន | រដ្ឋា | សមាជិកក្រុមប្រឹក្សាឃុំគោខ្ចក |
| ៤៦- | លោក | ស៊ិន | ឆាន | សមាជិកក្រុមប្រឹក្សាឃុំគោខ្ចក |
| ៤៧- | លោក | អ៊ិន | ចាន់ | សមាជិកក្រុមប្រឹក្សាឃុំអន្លង់ |
| ៤៨- | លោក | ថោង | សារី | សមាជិកក្រុមប្រឹក្សាឃុំអន្លង់ |
| ៤៩- | លោក | សេក | ម៉ុនធឿន | សមាជិកក្រុមប្រឹក្សាឃុំកំពង់ត្របែក |
| ៥០- | លោក | ជា | សាខន | សមាជិកក្រុមប្រឹក្សាឃុំកំពង់ត្របែក |
| ៥១- | លោក | គង់ | ប៊ិច | សមាជិកក្រុមប្រឹក្សាឃុំពាមមន្ទារ |
| ៥២- | លោក | មាស | ធុល | សមាជិកក្រុមប្រឹក្សាឃុំពាមមន្ទារ |

៥៣- លោក ពៅ សាមួន សមាជិកក្រុមប្រឹក្សាឃុំព្រៃឈរ
៥៤- លោក ឈាង សំរោត សមាជិកក្រុមប្រឹក្សាឃុំថ្កូវ
៥៥- លោក កែវ ទន្លា មេឃុំ ព្រៃពោន
៥៦- លោក ម៉ម យន សមាជិកក្រុមប្រឹក្សាឃុំព្រៃពោន
៥៧- លោក ខាន់ តាជ សមាជិកក្រុមប្រឹក្សាឃុំជ្រៃ
៥៨- លោក ទ៉ា សារឿន សមាជិកក្រុមប្រឹក្សាឃុំ កន្សោមអក
៥៩- លោក ជិន សារ៉េត សមាជិកក្រុមប្រឹក្សាឃុំ កន្សោមអក
៦០- លោក រស់ ឧត្តី អាជីវករ ផ្សារកអណ្តើក
៦១- លោក ជា សៀង ពាណិជ្ជករ រាជធានីភ្នំពេញ
៦២- លោក ឈាង ឌីម៉ា អាជីវករ ផ្សារកអណ្តើក
៦៣- លោក ទៅ លីមស៊ីម អាជីវករ ផ្សារកអណ្តើក
៦៤- លោក លឹម ស្រ៊ុន អាជីវករ ផ្សារកអណ្តើក
៦៥- លោក ស៊ាង ហៃ អាជីវករ ឃុំចាម
៦៦- លោក ញឹម សុផាន្នី អាជីវករ ផ្សារកំពង់ត្របែក
៦៧- លោក ទ៉ា ជួត អាជីវករ ផ្សារកំពង់ត្របែក
៦៨- លោក ពុត សារិទ្ធ អាជីវករ ផ្សារកំពង់ត្របែក
៦៩- លោក ខឹម សារ៉ន សប្បុរសជន ឃុំគោខ្ចក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ..៩១៤..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិត្យសភាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមសំណើរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

## សម្រេច

**មាត្រា ១ .-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិត្យសភាកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោកជំទាវ បណ្ឌិត **ខ្លួត ធីតា** | ប្រធានរាជបណ្ឌិត្យសភាកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម បណ្ឌិតរដ្ឋ **គិច សំណាង** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម បណ្ឌិត **ហ៊ាន សាហ៊ីប** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម បណ្ឌិត **ម៉ក់ ថាវិន** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥- ឯកឧត្តម បណ្ឌិត **ស៊ុំ ឈុំប៊ុន** | អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា | លេខាធិការ |

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានរាយនាមក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលប្រៃសណីយ៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យ លេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការការអនុវត្តព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យ លេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការបង្កើតប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រា ១:** តែងតាំងក្រុមប្រឹក្សាភិបាលប្រៃសណីយ៍កម្ពុជា ដែលមានសមាសភាពដូចខាងក្រោមៈ

១- ឯកឧត្តម **កែវ ឧត្តរិន** តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធាន

២- ឯកឧត្តម **សេង សត្ថា** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣- លោក **សាន់ សារទេ** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤- លោក **អេងភ ម៉ូរ៉ា** អគ្គនាយកប្រៃសណីយ៍កម្ពុជា សមាជិក

៥- តំណាងនិយោជិត ប្រៃសណីយ៍កម្ពុជា សមាជិក

**មាត្រា ២:** សមាសភាពក្រុមប្រឹក្សាភិបាល ដូចចែងក្នុងមាត្រា ១ ត្រូវបានតែងតាំងសម្រាប់រយៈពេល ០៣ ឆ្នាំ (បីឆ្នាំ) ។ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន ។

**មាត្រា ៣:** មុខងាររបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ចប់បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ដែលបានពិភាក្សាសម្រេចលើគណនីនៃកាលបរិច្ឆេទទី ៣ របស់ប្រៃសណីយ៍កម្ពុជា ។ សមាជិកក្រុមប្រឹក្សាភិបាលអាចត្រូវផ្លាស់ប្តូរដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងសាមី ។

**មាត្រា ៤:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការលុបឈ្មោះមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានលុបឈ្មោះលោក **ម៉ី លន់** ឋានន្តរស័ក្តិ**វរមន្ត្រី** ថ្នាក់លេខ **៦** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ ដោយមូលហេតុមរណភាព ចាប់ពីថ្ងៃទី **០១** ខែ **ឧសភា** ឆ្នាំ **២០១០**។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ទី៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៤ . សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន លោកវរសេនីយ៍ត្រី **ជុំ ពិសិដ្ឋ** អត្តលេខ ០១៩៨៦៨ នាយរងការិយាល័យសំភារៈ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ បច្ចុប្បន្នទៅបំរើការងារក្នុងក្របខ័ណ្ឌ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៖ ៥៦៩ សហវ.ពក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ចំពោះទំនិញនាំចេញ នាំចូល មន្ត្រីគយមានសិទ្ធិអំណាចដូចតទៅ ៖

ក. ពិនិត្យទំនិញ ហើយបើក ឬបញ្ជាឲ្យបើកកញ្ចប់ណាមួយ ឬកុងតឺន័រទំនិញ និងអាចដកយកទំនិញគម្រូបានក្នុងបរិមាណសមស្របសម្រាប់ការពិនិត្យ ។

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ខ. ឃាត់ បញ្ឈប់ ឡើង ចូល និងត្រួតពិនិត្យឆែកឆេរមធ្យោបាយដឹកជញ្ជូនណាមួយ និងបញ្ជាឲ្យនាំមធ្យោបាយដឹកជញ្ជូននោះទៅការិយាល័យគយ ឬទីកន្លែងសមស្របផ្សេងទៀត ដើម្បីធ្វើការត្រួតពិនិត្យ ឆែកឆេរ ។

គ. ឆែកឆេរលំនៅដ្ឋានឯកជន ឬទីកន្លែងធុរកិច្ច ដើម្បីប្រមូលភស្តុតាង ឬឃាត់ទុកទំនិញជាបណ្តោះអាសន្ន តាមបទប្បញ្ញត្តិ និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជាក្នុងករណីមានការសង្ស័យដែលមានមូលដ្ឋានគួរឱ្យទុកចិត្តបាន ថាមានការប្រព្រឹត្តបទល្មើស ។

ឃ. ត្រួតពិនិត្យអត្តសញ្ញាណជនណាមួយ ដែលចូលក្នុង ចេញពីដែនគយ ឃាត់ បញ្ឈប់ សួរ និងឆែកឆេរជននោះ ប្រសិនបើ មន្ត្រីគយសង្ស័យថា ជននោះមានលាក់ទំនិញ ឬរបស់អ្វីផ្សេងទៀត នៅជុំវិញខ្លួន និងនៅក្នុងខ្លួនរបស់គេ ដែលអាចជាភស្តុតាងនៃការរំលោភច្បាប់ស្តីពីគយ ឬច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

ការត្រួតពិនិត្យរូបវន្តរបស់រដ្ឋបាលគយនឹងត្រូវផ្អែកតាមការវាយតម្លៃហានិភ័យលើដើងដឹកជញ្ជូនទំនិញនីមួយៗ ហើយអាចមានការត្រួតពិនិត្យដោយផ្នែក ឬទាំងស្រុង អាចមិនមានការត្រួតពិនិត្យ ឬត្រួតពិនិត្យសារឡើងវិញនូវទំនិញ ។ ប្រសិនបើទំនិញមិនត្រូវបានត្រួតពិនិត្យរូបវន្ត រដ្ឋបាលគយត្រូវកំណត់ពន្ធ និងអាករដែលត្រូវបង់ដោយផ្អែកតាមប្រតិវេទន៍គយ ។

**ប្រការ ៣.-**

គោលបំណងនៃការត្រួតពិនិត្យរូបវន្តលើទំនិញ គឺដើម្បីផ្ទៀងផ្ទាត់អនុលោមភាពរវាងទំនិញពិត ជាមួយព័ត៌មាននៅក្នុងប្រតិវេទន៍គយ លើ បរិយាយមុខទំនិញ បរិមាណ ដើមកំណើត និងលក្ខណៈដទៃទៀត ។ ការត្រួតពិនិត្យរូបវន្តក៏អាចត្រូវបានធ្វើឡើងផងដែរ សម្រាប់គោលបំណងឆែកឆេររកទំនិញខុសច្បាប់ ឬទំនិញដែលមិនត្រូវបានប្រកាស ។

**ប្រការ ៤.-**

ទំនិញនាំចេញ នាំចូលទាំងអស់ ទោះបីជា ឬមិនមែនជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករក្តី និងមធ្យោបាយដឹកជញ្ជូនទំនិញទាំងនោះ ដែលចូលក្នុង ចេញពីដែនគយ ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ។ ម្ចាស់ទំនិញ ឬក៏បុគ្គលដែលទទួលខុសត្រូវចំពោះទំនិញទាំងនោះ ត្រូវរៀបចំទំនិញជូនមន្ត្រីគយ ដើម្បីអាចត្រួតពិនិត្យបាន រាប់បញ្ចូលទាំងការរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូន ការបើកកញ្ចប់ ការផ្ទុកទំនិញត្រឡប់ទៅក្នុងមធ្យោបាយដឹកជញ្ជូនវិញ និងការបិទកញ្ចប់ទំនិញឡើងវិញ ស្របតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីគយ ។

**ប្រការ ៥.-**

ក្រោយពីប្រតិវេទន៍គយត្រូវបានចុះបញ្ជិការួច រដ្ឋបាលគយត្រូវកំណត់ពេលវេលាមួយដើម្បីធ្វើការត្រួតពិនិត្យទំនិញ ។

ការត្រួតពិនិត្យទំនិញ អាចត្រូវបានធ្វើឡើងមុនការចុះបញ្ជិកាប្រតិវេទន៍គយ ប្រសិនបើមានការអនុញ្ញាតជាមុនពីអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

ជាធម្មតា ការត្រួតពិនិត្យគយនឹងត្រូវបានធ្វើឡើងក្នុងពេលម៉ោងធ្វើការរបស់ការិយាល័យគយ។ ក្នុងករណីដែលការត្រួតពិនិត្យត្រូវបានធ្វើឡើងក្រោយពេលម៉ោងធ្វើការរបស់ការិយាល័យគយតាមការកំណត់របស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា អ្នកនាំចូល អ្នកនាំចេញ ឬអ្នកតំណាង ត្រូវបង់ថ្លៃចំណាយក្នុងការធ្វើការបន្ថែមម៉ោងដោយមន្ត្រីគយដែលធ្វើការត្រួតពិនិត្យ រាប់បញ្ចូលទាំង រយៈពេលធ្វើដំណើរ ផ្អែកតាមអត្រាដែលនឹងត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦.-**

ការត្រួតពិនិត្យទំនិញនាំចេញ ឬនាំចូល នឹងត្រូវធ្វើឡើងតែក្នុងទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាតប៉ុណ្ណោះ រាប់បញ្ចូលទាំង សន្និធិគយបណ្តោះអាសន្ន និងកណ្តាគារគយមានដែនកំណត់ផងដែរ ។ តាមសំណើរបស់អ្នកនាំចូល ឬក៏បុគ្គលដែលកាន់រក្សាទំនិញ រដ្ឋបាលគយអាចអនុញ្ញាតឲ្យមានការត្រួតពិនិត្យនៅទីកន្លែងមួយផ្សេងសម្រាប់គោលបំណងនេះ រាប់បញ្ចូលទាំងអាជីវកម្មដ្ឋានរបស់ម្ចាស់ទំនិញ ឬអ្នកនាំចូល ឬក៏ទីតាំងផ្សេងទៀត ស្របតាមបញ្ញត្តិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុញ្ញាតឱ្យបំពេញទម្រង់ការគយ នៅក្រៅការិយាល័យគយ ។

**ប្រការ ៧.-**

ការផ្ទៀងផ្ទាត់ទំនិញត្រូវធ្វើឡើងដោយមានវត្តមានរបស់ម្ចាស់ទំនិញ ឬអ្នកតំណាងម្ចាស់ទំនិញ ដែលមានសិទ្ធិជំទាស់នឹងលទ្ធផលនានានៃការត្រួតពិនិត្យណាមួយរួមទាំងការត្រួតពិនិត្យដោយផ្នែក និងអាចស្នើសុំឲ្យមានការផ្ទៀងផ្ទាត់ ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញ ឬការត្រួតពិនិត្យទាំងស្រុង ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នា ។

**ប្រការ ៨ .-**

នៅពេលដែលម្ចាស់ទំនិញ ឬអ្នកតំណាង មិនបង្ហាញខ្លួនដើម្បីចូលរួមក្នុងការត្រួតពិនិត្យ រដ្ឋបាលគយត្រូវជូនដំណឹងដល់អ្នកទាំងនោះ តាមរយៈលិខិតអនុសិដ្ឋអំពីការត្រៀមចាប់ផ្តើមប្រតិបត្តិការត្រួតពិនិត្យ ឬបន្តការត្រួតពិនិត្យ ប្រសិនបើការត្រួតពិនិត្យនោះត្រូវបានផ្អាកជាបណ្តោះអាសន្ន ។ ប្រសិនបើហួសរយៈពេលដប់ប្រាំ (១៥) ថ្ងៃ បន្ទាប់ពី

ការជូនដំណឹង នៅតែមិនមានលទ្ធផលនោះ ប្រធានការិយាល័យគយពាក់ព័ន្ធ អាចស្នើសុំតុលាការមានសមត្ថកិច្ច ដើម្បីចាត់តាំងបុគ្គលណាម្នាក់ជាតំណាងប្រតិវេទន៍ករដែលខកខានបង្ហាញខ្លួន ដើម្បីចូលរួមក្នុងការត្រួតពិនិត្យ ។

**ប្រការ ៩ .-**

នៅពេលមិនមានព័ត៌មានចាំបាច់សម្រាប់ការបំពេញប្រតិវេទន៍គយ ម្ចាស់ទំនិញ ឬអ្នកតំណាងអាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយដើម្បីពិនិត្យទំនិញ ហើយប្រសិនបើមានការតម្រូវ អាចដកគំរូទំនិញមុនពេលត្រួតពិនិត្យ ។ ម្ចាស់ទំនិញ ឬអ្នកតំណាងត្រូវដាក់ជូនរដ្ឋបាលគយនូវប្រតិវេទន៍គយបណ្តោះអាសន្នមួយ តែមិនមានន័យថា ពួកគេអាចរួចផុតពីកាតព្វកិច្ចនៃការតម្កល់ប្រតិវេទន៍គយទេ ។ រដ្ឋបាលគយមានសិទ្ធិស្នើសុំឱ្យម្ចាស់ទំនិញប្រគល់មកវិញនូវទំនិញគំរូ ឬរក្សាទុកជា ម៉ូដែល ។

ការលើកដាក់ ផ្ទេរ ឬកែលម្អណាមួយ ដែលអាចបណ្តាលឲ្យមានការផ្លាស់ប្តូររូបរាងខាងក្រៅ ឬលក្ខណៈទំនិញដែលជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍បណ្តោះអាសន្នត្រូវបានហាមឃាត់ ។

ទម្រង់នៃប្រតិវេទន៍បណ្តោះអាសន្ន និងលក្ខខណ្ឌនានាពាក់ព័ន្ធនឹងលទ្ធភាពនៃការត្រួតពិនិត្យបឋមលើទំនិញ ត្រូវកំណត់ដោយអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ១០ .-**

ទំនិញឆាប់ខូច ឬទំនិញគ្រោះថ្នាក់លំបាករក្សាទុក រាប់បញ្ចូលទាំងបន្លែ ផ្លែឈើ សាច់ស្រស់ សត្វរស់ ផលិតផល និងទំនិញបង្កក ដែលត្រូវការ ការរក្សាទុកក្នុងសន្និធិពិសេសដោយឡែកនឹងត្រូវបានផ្តល់អាទិភាពសម្រាប់ការត្រួតពិនិត្យ ។

**ប្រការ ១១ .-**

មន្ត្រីគយមានសមត្ថកិច្ចត្រូវរៀបចំជារបាយការណ៍ត្រួតពិនិត្យក្នុងទម្រង់ នៃប្រតិវេទន៍គយតាមរបៀបពេញលេញ និងត្រឹមត្រូវ ។ របាយការណ៍ ត្រូវបានកត់សម្គាល់នូវភាពមិនប្រក្រតីណាមួយ និងសកម្មភាពមិនសមរម្យរបស់ម្ចាស់ទំនិញ ឬអ្នកតំណាង ។

**ប្រការ ១២ .-**

ទំនិញនាំចេញ នាំចូលដោយបេសកកម្មកុងស៊ុល ឬការទូតបរទេស ឬគណៈប្រតិភូផ្លូវការនៃរដ្ឋាភិបាលបរទេស ត្រូវបានរួចផុតពីការត្រួតពិនិត្យរូបវន្តដោយមន្ត្រីគយ ។ មន្ត្រីគយត្រូវរាយការណ៍ជូនថ្នាក់លើ របស់ខ្លួន អំពីទំនិញ ឬជើងដឹកជញ្ជូនណាមួយដែលគួរឱ្យសង្ស័យពាក់ព័ន្ធនឹងទំនិញទាំងនេះ ដើម្បីអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ។

**ប្រការ ១៣ .-**

មន្ត្រីគយមានសិទ្ធិចូលទៅគ្រប់ទីកន្លែង នៃការិយាល័យប្រៃសណីយ៍ ដែលដំណើរការបញ្ជូនកញ្ចប់ប្រៃសណីយ៍អន្តរជាតិ ដើម្បីឆែកឆេរក នៅចំពោះមុខមន្ត្រីប្រៃសណីយ៍ នូវកញ្ចប់ប្រៃសណីយ៍ដែលមានដើមកំណើតក្នុងស្រុក និងបរទេសទាំងឡាយណាដែលផ្ទុក ឬត្រូវបានជឿជាក់ថា មានផ្ទុកទំនិញនានាដូចមានចែងក្នុងបញ្ញត្តិប្រការ ១២ នៃប្រកាសនេះ ។

**ប្រការ ១៤ .-**

តាមបញ្ញត្តិអនុសញ្ញា និងការសម្របសម្រួលរបស់សហភាពប្រៃសណីយ៍សាកលអាជ្ញាធរប្រៃសណីយ៍ត្រូវបង្កការងាយស្រួលជូនរដ្ឋបាលគយ ក្នុងការត្រួតពិនិត្យនូវកញ្ចប់ប្រៃសណីយ៍ទាំងឡាយណាដែលជាកម្មវត្ថុនៃការ ជាប់ពន្ធ ជាប់ការត្រួតពិនិត្យគយ ឬជាប់អាយ័តភាព ឬកម្រិតកំណត់នានា ។

**ប្រការ ១៥ .-**

ការត្រួតពិនិត្យនឹងមិនត្រូវធ្វើលើបណ្តាកញ្ចប់ប្រៃសណីយ៍ទាំងឡាយ ដូចខាងក្រោម ៖

ក. ប្រៃសណីយ៍បត្រនិងលិខិតដែលមានតែសារផ្ទាល់ខ្លួន អក្សរសាស្ត្រសម្រាប់មនុស្សពិការភ្នែក

ខ. ឯកសារបោះពុម្ពដែលមិនមែនជាកម្មវត្ថុនៃការជាប់ពន្ធ

គ. កញ្ចប់ប្រៃសណីយ៍ដែលដឹកជញ្ជូនឆ្លងកាត់ជាអន្តរជាតិ

**ប្រការ ១៦ .-**

ការត្រួតពិនិត្យកញ្ចប់ប្រៃសណីយ៍ដោយមន្ត្រីគយ ត្រូវប្រព្រឹត្តទៅដោយមានវត្តមានមន្ត្រីប្រៃសណីយ៍ ឬម្ចាស់កញ្ចប់ប្រៃសណីយ៍នោះ ។

**ប្រការ ១៧ .-**

ក្នុងគោលបំណងឆែកឆេរកទំនិញមិនបានប្រកាស ឬទំនិញខុសច្បាប់ មន្ត្រីគយអាចចូល ឬឆែកឆេររាល់នាវាទាំងឡាយណាដែលស្ថិតក្នុងវង្វង់មណ្ឌលសមុទ្រនៃវង់អំណាចគយ ដែលបានបោះយុថ្កាឈប់នៅតាមកំពង់ផែដែលមានការិយាល័យគយតាមបណ្តោយឆ្នេរ ឬតាមនាវាដែលកំពុងធ្វើចរាចរក្នុងទន្លេ ព្រែក ឬប្រឡាយនានា ។ មន្ត្រីគយអាចស្ថិតនៅលើនាវារហូតដល់នាវានោះត្រូវបានរើទំនិញចេញរួច ឬត្រូវបានចាកចេញទៅវិញ ។

**ប្រការ ១៨.-**

នាវាបតី និងនាយនាវានានា ត្រូវសហការជាមួយមន្ត្រីគយ និងជួយសម្រួលឱ្យការត្រួតពិនិត្យដំណើរការបានល្អ រាប់បញ្ចូលទាំងការបើក បិទឃ្លុបនាវា បន្ទប់ ទូ និងកញ្ចប់នានា ។ រាល់ចំណាយសម្រាប់ការត្រួតពិនិត្យជាបន្ទុករបស់នាវាបតី និងនាយនាវា ។ ប្រសិនបើនាវាបតី និងនាយនាវា បដិសេធ មន្ត្រីគយអាចស្នើសុំជំនួយពីតុលាការមានសមត្ថកិច្ចដើម្បីតម្រូវឲ្យបើកពិនិត្យមើល ឃ្លុបនាវា បន្ទប់ ទូ និងកញ្ចប់នានាទាំងនោះ ។

**ប្រការ ១៩.-**

នៅម៉ោង ប្រាំមួយ ល្ងាច មន្ត្រីគយដែលកំពុងត្រួតពិនិត្យនាវា និងទំនិញ អាចបិទឃ្លុបនាវា ដែលអាចនឹងត្រូវបើកឡើងវិញ តែនៅពេលមានវត្តមានរបស់មន្ត្រីគយទាំងនោះប៉ុណ្ណោះ ។

**ប្រការ ២០.-**

នៅពេលត្រួតពិនិត្យអាកាសយាន មន្ត្រីគយត្រូវធានាថា មានអ្នកបច្ចេកទេសអាកាសយានដែលមានគុណវុឌ្ឍិម្នាក់អមពួកគេ ។ អ្នកបច្ចេកទេសនេះត្រូវបានផ្តល់ដោយអាកាសយានបតី ដើម្បីធានាថា ការត្រួតពិនិត្យនឹងមិនបណ្តាលឲ្យមានការខូចខាត ឬប៉ះពាល់ដល់សុវត្ថិភាពណាមួយរបស់អាកាសយានឡើយ ។

**ប្រការ ២១.-**

នៅពេលត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនផ្លូវគោក អ្នកបើកបរមធ្យោបាយដឹកជញ្ជូន ត្រូវជួយមន្ត្រីគយក្នុងដំណើរការត្រួតពិនិត្យ ដោយធានាសុវត្ថិភាពមធ្យោបាយដឹកជញ្ជូន ដោយបើកឃ្លុប ឬបន្ទះគម្របនានា និងដោយដោះបំណែក ឬគ្រឿងបន្ទាប់បន្សំណាមួយ តាមសំណើរបស់មន្ត្រីគយ ។

**ប្រការ ២២.-**

អ្នកបើកបរមធ្យោបាយដឹកជញ្ជូនត្រូវគោរពតាមបញ្ជារបស់មន្ត្រីគយ ក្នុងការធ្វើចលនាមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន ។

មន្ត្រីគយអាចប្រើប្រាស់បរិក្ខារសមស្របដើម្បីឃាត់បញ្ឈប់មធ្យោបាយដឹកជញ្ជូនកាលបើអ្នកបើកបរមិនឈប់តាមការបញ្ជាឲ្យឈប់ ។

**ប្រការ ២៣.-**

អគ្គនាយកគយ និងរដ្ឋាករកម្ពុជាអាចចេញសេចក្តីណែនាំ ស្តីពីការត្រួតពិនិត្យរូបវន្តលើទំនិញ លើលំនៅដ្ឋានឯកជន ឬអាជីវកម្មដ្ឋាន ការឆែកអត្តសញ្ញាណបុគ្គលណាមួយ និងការឆែកឆេរជុំវិញ និងក្នុងខ្លួនបុគ្គលនានា ដើម្បីប្រមូលភ័ស្តុតាង ឬឃាត់ទុកជាបណ្តោះអាសន្ននូវទំនិញ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននានា ។

**ប្រការ ២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២៥ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ២៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៥៧០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## នីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀត អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅ អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ក្នុងអំឡុងពេលសាមសិប ( ៣០ ) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីទោសទណ្ឌ ឬ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
No.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ការឃាត់ទុក ដោយបញ្ជាក់ ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិជានាស្របតាមបញ្ញត្តិ មាត្រា ៤១ នៃច្បាប់ស្តីពីគយ ។

**ប្រការ ២.-**

អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ លើការតវ៉ាក្នុងអំឡុងពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវបានចាត់ទុកថា បានទទួលការយល់ព្រម ។

**ប្រការ ៣ .-**

ការតវ៉ាអាចត្រូវបានតម្កល់នៅតាមអង្គភាពគយ ដូចខាងក្រោម ៖

- ការិយាល័យគយដែលតាក់តែងកំណត់ហេតុ ឬកំណត់ការពិន័យ
- សាខាគយ និងរដ្ឋាករពាក់ព័ន្ធ
- ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

បន្ទាប់ពីបានទទួលការតវ៉ា អង្គភាពគយពាក់ព័ន្ធត្រូវបញ្ជូនលិខិតសុំតវ៉ានោះដោយមិនបង្អែបង្អង់ជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤ .-**

លិខិតសុំតវ៉ាត្រូវមាននូវព័ត៌មានដូចតទៅ ៖

- នាម អាសយដ្ឋាន និងហត្ថលេខា របស់បុគ្គលដែលតម្កល់ការតវ៉ា
- សេចក្តីលម្អិតនៃកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុឃាត់ទុកបណ្តោះអាសន្ន រាប់បញ្ចូលទាំងសេចក្តីថតចម្លងកំណត់ហេតុទាំងនេះ
- សេចក្តីពន្យល់អំពីមូលហេតុនៃការតវ៉ា ។

**ប្រការ ៥ .-**

ប្រសិនបើទំនិញឃាត់ទុកបណ្តោះអាសន្នមិនជាប់អាយ័ត ទំនិញ មធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុចាប់ឃាត់ផ្សេងទៀតមិនតម្រូវសម្រាប់ជាភស្តុតាង វត្ថុឃាត់ទុកទាំងនេះអាចត្រូវបានប្រគល់ទៅម្ចាស់ ក្រោយពេលបានតម្កល់នូវនិមុត្តិជានាដូចមានចែងក្នុងបញ្ញត្តិនៃប្រកាសស្តីពីនិមុត្តិជានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ។

ប្រសិនបើអគ្គនាយកគយ និងរដ្ឋាករកម្ពុជា មិនយល់ព្រមតាមការតវ៉ាទេ បុគ្គលដែលបានដាក់ពាក្យតវ៉ា មានសិទ្ធិតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច រាប់បញ្ចូលទាំងតុលាការមានសមត្ថកិច្ច ចំពោះការសម្រេចរបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។ ការតវ៉ានេះត្រូវធ្វើក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិពករណ៍ ។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៧២ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការបង់ពន្ធ និងអាករ លើទំនិញនាំចេញ និងទំនិញនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញាឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ទំនិញនាំចូល ឬទំនិញនាំចេញទាំងឡាយ ពុំអាចយកចេញពីការិយាល័យគយ សន្និធិគយបណ្តោះអាសន្ន ឬកណ្តាគារគយមានដែនកំណត់បានទេ មុនពេលដែល ពន្ធ អាករ កម្រៃផ្សេងៗ ប្រាក់ពិន័យ ការប្រាក់ និងបន្ទុកនានាត្រូវបានទូទាត់ ឬមានការធានាដោយនិមុត្តិជានាដែលមានការឯកភាពពីរដ្ឋបាលគយ ។

ទំនិញពុំអាចត្រូវបានយកចេញពីទីកន្លែង ដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌទីមួយនៃប្រការនេះ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

បន្ទាប់ពីទទួលបានការអនុញ្ញាតពីរដ្ឋបាលគយ ទំនិញត្រូវបានយកចេញជាបន្ទាន់ពីទីកន្លែងដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌទីមួយនៃប្រការនេះ ។

**ប្រការ ២ .-**

ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាត្រូវបានគណនាលើប្រតិវេទន៍គយ ដែលត្រូវបានផ្ទៀងផ្ទាត់រួចដោយមន្ត្រីគយ ។

**ប្រការ ៣ .-**

ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាដែលត្រូវបង់សម្រាប់មុខទំនិញនីមួយៗ ក្នុងប្រតិវេទន៍គយតែមួយ ត្រូវគិតជាប្រាក់រៀលដោយតម្លើងដល់ខ្ទង់រយជិតបំផុត ។

**ប្រការ ៤ .-**

ការបង់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាត្រូវធ្វើនៅតាមការិយាល័យគយមានសមត្ថកិច្ចក្នុងពេលម៉ោងធ្វើការ បន្ទាប់ពីការចុះបញ្ជិកាប្រតិវេទន៍គយដោយមន្ត្រីគយ និងនៅមុនពេលត្រួតពិនិត្យរូបវន្តលើទំនិញ ក្នុងករណីចាំបាច់ ។

ការបង់ប្រាក់នេះអាចធ្វើឡើងក្រោយពេលត្រួតពិនិត្យរូបវន្តលើទំនិញ ប្រសិនបើមានការអនុញ្ញាតដោយឡែកពីអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥ .-**

អ្នកនាំចេញ អ្នកនាំចូល ឬម្ចាស់ទំនិញ ត្រូវទទួលខុសត្រូវចំពោះ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា លើទំនិញនាំចេញ និងទំនិញនាំចូល ។

ក្នុងករណីដែល អ្នកនាំចេញ អ្នកនាំចូល ឬម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសារគយត្រូវទទួលខុសត្រូវចំពោះ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាលើទំនិញនាំចេញ និងទំនិញនាំចូល ។

ក្នុងករណីសន្និធិគយបណ្ដោះអាសន្ន ឬកណ្ដាគារគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិ និងកណ្ដាគារទាំងនេះ ជាអ្នកទទួលខុសត្រូវចំពោះ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលអាចត្រូវទទួល រហូតដល់ទំនិញត្រូវបាននាំចេញទៅវិញ នាំចូលបណ្ដោះអាសន្ន នាំចូលដើម្បីប្រើប្រាស់ក្នុងប្រទេស បង្វែរទៅទីកន្លែងសន្និធិ ឬកណ្ដាគារផ្សេងទៀត ឬបំផ្លាញចោល ដោយមានការអនុញ្ញាតពីរដ្ឋបាលគយ ។

នៅក្នុងករណីមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីគយ ប្រសិនបើលក្ខខណ្ឌនៃការលើកលែងពន្ធ និងអាករ មិនត្រូវបានបំពេញសព្វគ្រប់ ការទទួលខុសត្រូវចំពោះពន្ធ និងអាករ ជាបន្ទុករបស់បុគ្គលដែលបានទទួលការលើកលែងពន្ធ និងអាករ ។ ប្រសិនជាមិនអាចរកឃើញបុគ្គលនោះ បន្ទុកនេះត្រូវធ្លាក់លើបុគ្គលដែលកាន់កាប់ទំនិញទាំងនេះ ។

ជនណាដែលជាអ្នកកាន់កាប់ទំនិញនាំចូល នាពេលដែលមធ្យោបាយដឹកជញ្ជូនចូលក្នុងដែនគយ រាប់បញ្ចូលទាំងប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនផង ជននោះជាអ្នកទទួលខុសត្រូវលើពន្ធ អាករ នាំចូលនៃទំនិញនោះ ។

**ប្រការ ៦ .-**

ពន្ធ អាករ កម្រៃផ្សេងៗ ពិន័យ និងបន្ទុកនានាត្រូវបានបង់ជាប្រាក់រៀលក្នុងទម្រង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬទម្រង់ផ្សេងទៀតនៃលិខិតុបករណ៍ហិរញ្ញវត្ថុដែលទទួលស្គាល់ និងអនុញ្ញាតដាក់ឲ្យប្រើប្រាស់ដោយធនាគារជាតិនៃកម្ពុជា ។

ការបង់អាចត្រូវបានធ្វើដោយការផ្ទេរមូលនិធិតាមប្រព័ន្ធអេឡិកត្រូនិច ស្របតាមលក្ខខណ្ឌ និងនីតិវិធីនានាដែលអាចកំណត់ដោយរដ្ឋបាលគយ និងធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៧ .-**

រដ្ឋបាលគយ ត្រូវទទួលស្គាល់បង្កាន់ដៃផ្លូវការដែលចេញដោយធនាគារជាតិ នៃកម្ពុជា ស្របតាមបញ្ញត្តិប្រការ ៦ ខាងលើ ដោយចាត់ទុកជា ទឡ្ហីករណ៍ នៃការបង់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា ។

**ប្រការ ៨ .-**

រដ្ឋបាលគយត្រូវចេញបង្កាន់ដៃផ្លូវការសម្រាប់រាល់ការទទួលប្រាក់ដែលបានបង់ទាំងអស់ ។

**ប្រការ ៩ .-**

រដ្ឋបាលគយអាចអនុញ្ញាតឲ្យយកទំនិញពីគយ មុនពេលបង់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា ប្រសិនបើមានការតម្កល់ការធានា ជាសាច់ប្រាក់ ឬជានិមុត្តិធានាស្របតាមបញ្ញត្តិប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនិមុត្តិធានាជាធរមាន ។

បុគ្គលដែលមានបំណងទទួលនូវគុណប្រយោជន៍ពីនីតិវិធីនេះ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលគយ ដោយភ្ជាប់ជាមួយនូវនិមុត្តិធានា ។ បុគ្គលដែលមានបំណងប្រើប្រាស់និមុត្តិធានារយៈពេលវែង សម្រាប់ការប្រើប្រាស់ច្រើនដងជាបន្តបន្ទាប់ត្រូវតែតម្កល់និមុត្តិធានា គ្រប់គ្រាន់ ដែលអាចធានាបាននូវ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាដែល

អាចកើតមានឡើង ។ និមុត្តិធានាទាំងនេះ ត្រូវគ្រប់គ្រងឃ្លាំមើលដោយរដ្ឋបាលគយ ដើម្បីធានាថា ពន្ធ អាករ កម្រៃផ្សេងៗ ការប្រាក់ និងបន្ទុកនានា នឹងមិនលើសពីតម្លៃនិមុត្តិធានាឡើយ ។

ការទូទាត់ទាំងស្រុងនូវទឹកប្រាក់ដែលត្រូវបង់ត្រូវធ្វើឡើងក្នុងរង្វង់ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃអនុញ្ញាតឱ្យយកទំនិញចេញពីគយ ។ ការខកខានទូទាត់ដូចនេះ នឹងត្រូវរងនូវវិធានការគយក្នុងការប្រមូលបំណុល ស្របតាមបញ្ញត្តិមាត្រា ៣៨ មាត្រា ៣៩ និងមាត្រា ៤០ នៃច្បាប់ស្តីពីគយ ។

**ប្រការ ១០ .-**

ក្នុងករណីមានវិវាទ ឬការតវ៉ាពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាដែលត្រូវបង់ អ្នកនាំចេញ អ្នកនាំចូល ម្ចាស់ទំនិញ ឬតំណាងរបស់ខ្លួនអាចត្រូវបានអនុញ្ញាតឲ្យយកទំនិញចេញពីគយ ក្រោយពីបានតម្កល់ប្រាក់ធានា ឬនិមុត្តិធានាដែលមានការយល់ព្រមពីរដ្ឋបាលគយស្របតាមបទប្បញ្ញត្តិជាធរមាន ក្នុងពេលរង់ចាំការសម្រេចជាផ្លូវការលើការតវ៉ា ឬវិវាទនេះ ។

**ប្រការ ១១ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា " ដើម្បីជូនជ្រាប "
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧ ០១០ ១៥០ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើ
## គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាមានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមការអនុម័តិរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើឯកភាពគ្នានៅក្នុងប្រព័ន្ធធនាគារនូវគំរូបញ្ជាទូទាត់ សម្រាប់ការទូទាត់សងប្រាក់ជាលាយលក្ខណ៍អក្សរឬជាអេឡិចត្រូនិក ដែលមានទម្រង់ជាការផ្ទេរឥណទាន ។

បញ្ជាទូទាត់នេះនឹងត្រូវបានប្រើ ដើម្បីផ្ទេរប្រាក់ពីគណនីរបស់អ្នកសងប្រាក់ទៅគណនីរបស់អ្នកទទួលប្រាក់ ដែលគណនីទាំងនេះអាចមាន ឬមិនមាននៅក្នុងធនាគារ ឬសាខាធនាគារជាមួយគ្នា ។

**ប្រការ ២.-**

បញ្ជាទូទាត់ត្រូវបានប្រើជាឧបករណ៍ស្របច្បាប់ អនុលោមតាមមាត្រា ១៩៩, ២០០, ២០១ និង ២០២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ បញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានត្រូវបានរៀបចំឱ្យមានលក្ខណៈស្តង់ដារច្បាស់លាស់ និងគ្រប់គ្រាន់ អំពីទម្រង់ ទិន្នន័យ និងព័ត៌មាន ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។

**ប្រការ ៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១០

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល ៖**

- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន ៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.............................................................

## ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩.០១០.១៥០ ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

## លក្ខណៈស្តង់ដារនៃបញ្ជាទូទាត់

ទម្រង់ ទិន្នន័យ និងព័ត៌មាន ដែលត្រូវបំពេញនៅក្នុងបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាលាយលក្ខណ៍អក្សរ និងអេឡិចត្រូនិក ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានបី ដូចខាងក្រោមៈ

- SWIFT
- សារប័ណ្ណ(Card Message)
- មូលប្បទានប័ត្រស្តង់ដារ ដូចមានចែងនៅក្នុងប្រកាសលេខ ធ៩-០៨-១៨៦ និងឧបសម្ព័ន្ធនៃប្រកាសនេះ។

### ១-តារាង ទិន្នន័យ និងព័ត៌មាននៃការផ្ទេរឥណទាន

| ឈ្មោះខ្លឹមសារ | ទម្រង់ខ្លឹមសារ | ការពន្យល់ |
|---|---|---|
| លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់ | ៦ ខ្ទង់ | លេខកូដតំណាងឱ្យ "ការផ្ទេរឥណទាន" (ជាកាតព្វកិច្ច) |
| កាលបរិច្ឆេទ | ៨ ខ្ទង់ | ថ្ងៃ - ខែ - ឆ្នាំ (00-00-0000) (ជាកាតព្វកិច្ច) |
| លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ | ៦ ខ្ទង់ | ៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីអ្នកសងប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |

| | | |
|---|---|---|
| ឈ្មោះអ្នកសងប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកសងប្រាក់ | ៣០ អក្សរ និង/ឬលេខ | (ជាជម្រើស) |
| ចំនួនប្រាក់ | ១៥ ខ្ទង់ | ១៥ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| លេខកូដរូបិយប័ណ្ណ | ៣ ខ្ទង់ | ៣ខ្ទង់តំណាងឱ្យរូបិយប័ណ្ណ ឧទាហរណ៍ KHR ឬ USD (ជាកាតព្វកិច្ច) |
| លេខកូដសុវត្ថិភាព | ១៨ ខ្ទង់ | តំណាងឱ្យលេខកូដសម្រាប់ផ្ទៀងផ្ទាត់ប្រតិបត្តិការ (ម៉ាស៊ីនគណនាដោយស្វ័យប្រវត្តិ) |
| លេខសម្គាល់អត្តសញ្ញាណធនាគារទទួលប្រាក់ | ៦ ខ្ទង់ | ៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារទទួលប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីរបស់អ្នកទទួលប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| ឈ្មោះអ្នកទទួលប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកទទួលប្រាក់ | ៣០អក្សរ និង/ឬលេខ | (ជាជម្រើស) |

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B9.010.150 P.K

*Unofficial Translation*

# PRAKAS

## on

## The Introduction of Payment Order Format for Credit Remittance

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13, dated November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Kram NS/RKM/1005/030, dated October 24, 2005 promulgating the Law on Negotiable Instruments and Payment Transactions;
- With reference to the Royal Kram NS/RKM/1206/036, dated December 29, 2006 promulgating the amendment of articles 14 and 57 of the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Degree NS/0508/526, dated May 13, 2008 on the reappointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, as equivalent to Senior Minister;
- Pursuant to the agreement reached at the meeting of the senior officials of the National Bank of Cambodia on August 16, 2010.

**D E C I D E S**

**Article 1.**

Introduce the uniform payment order into the banking system for the payment in written or electronic form which serves as the credit remittance.

The payment order will be used in order to transfer funds from payer's account to payee's account where these accounts may or may not be domiciled the same bank or bank branch.

**Article 2.**

The payment order is used as a legal instrument in compliance with Articles 199, 200, 201 and 202 of the Law on Negotiable Instruments and Payment Transactions. The payment order for the credit remittance shall be standardised and specified in terms of the format and data elements, and information as stated in Appendix to this Prakas.

**Article 3.**

The General Directorate, the General Secretariat, the General Cashier, the General Inspection, all Departments and branches of the National Bank of Cambodia, and all Banking Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 4.**

This Prakas shall have effect from the issuing date.

Phnom Penh, August 25, 2010

**The Governor**

Signed and Sealed: **CHEA CHANTO**

CC:

- As mentioned in article 3
  " for execution "
- The member of the Board of Directors
- File
- CM
  " for info"
- Administration Department of CM
  " for publication in the National Gazette "

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.......................................................

*Unofficial Translation*

# Appendix

Prakas N° B9. 10.150 P.K Dated August 25, 2010

## Formal Specification of Payment Order

Format Data and Information to be contained in the Payment Order for Credit Remittance in either written or electronic form are based on three primaries as follows:

- SWIFT
- Card Message Standard
- Check Standard – as set out in Prakas B9-08-186 and the accompanying Appendix

### 1-TABLE OF CREDIT REMITTANCE INFORMATION: CONTENTS AND FORMAT

| NAME OF CONTENTS | FORMAT OF CONTENTS | COMMENT |
|---|---|---|
| Payment Type Code | 6 numerals | Code equates to "Credit Remittance" (Mandatory) |
| Date | 8 numerals | DDMMYYYY (Mandatory) |
| Payer Bank/Branch Number | 6 numerals | 3 for Bank ID,<br>3 for HO or Branch ID (Mandatory) |
| Check Digit | 1 numeral | Associated with the Bank/HO or Branch Codes (Mandatory) |
| Payer Account Number | 12 numerals | 12 or if less consecutive spaces may be used (Mandatory) |
| Payer Name | 35 alpha characters and/or numerals | (Mandatory) |
| Payer Reference | 30 alpha characters and/or numerals | (Optional) |



P.O Box25, 22-24 Preah Norodom Blvd., Phnom Penh,Cambodia
Phone : 855 23 722563
Fax/Phone : 855 23 426117

| | | |
|---|---|---|
| Amount | 15 numerals | 15 or if less consecutive spaces may be used (Mandatory) |
| Currency Code | 3 numerals | 3 for Currency example KHR or USD (Mandatory) |
| Security Code | 18 numerals | Equates to a "Digital Signature" (Generated by system) |
| Payee Bank/Branch Number | 6 numerals | 3 for Bank ID,<br>3 for HO or Branch ID (Mandatory) |
| Check Digit | 1 numeral | Associated with the Bank/HO or Branch Codes (Mandatory) |
| Payee Account Number | 12 numerals | 12 or if less consecutive spaces may be used (Mandatory) |
| Payee Name | 35 alpha characters and/or numerals | (Mandatory) |
| Payee Reference | 30 alpha characters and/or numerals | (Optional) |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ២.៨៤២ ឧ.រ.ថ.ក.ឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៨៩២ /១០ គ.វ.ក ចុះថ្ងៃទី០៤.០៥.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន សាង ឈីង អ៊ីមប្រយរើរី ចុះថ្ងៃទី១៩.០៤.២០១០

## ស ម្រេ ច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន សាង ឈីង អ៊ីមប្រយរើរី តំណាងដោយលោកស្រី LIU, CHIU-HSUEH សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131263323 ចុះថ្ងៃ ទី ២០.០២.២០០១ មានអាសយដ្ឋានបច្ចុប្បន្ន៖ Shang Ching, ADD No.523 Long 8 Hang Yung Zhong He Taipei Hsien, Taiwan ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
| --- | --- |
| ប៉ាក់សម្លៀកបំពាក់ | ៣២១២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ផ្លាកឈ្មោះរោងចក្រ ៖ " *សាង ឈីង អ៊ីមប្រយឌើរី (SHANG CHING EMBROIDERY CO., LTD.)* "

-ទីតាំងរោងចក្រ ៖" *អាគារ B ផ្លូវជាតិលេខ៤ ភូមិអង្គស្នួលទី២ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល* "

<u>ប្រការ២:</u> -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

<u>ប្រការ៣:</u> -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

<u>ប្រការ៤:</u> ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

<u>ប្រការ៥:</u> ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

<u>ប្រការ៦:</u> ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន *ជាអក្សរខ្មែរមានទំហំធំជាង* និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**Ministry of Industry, Mines and Energy**

លេខៈ ៦៨៧ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែសីហាឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ ៥៣៥ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១២.០៦.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អង្គរ យៃនវើស ខូអិលធីឌី ចុះថ្ងៃទី០៨.០៧.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អង្គរ យៃនវើស ខូអិលធីឌី តំណាងដោយ លោកស្រី XU DANSHA សញ្ជាតិចិន អាយុ៤២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G25480254 ចុះថ្ងៃទី២៨.០៩.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន៖ St. 338 (CHUN YUAN, QIN ZHOU, NING BO, CHINA ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| -ស៊ីមរូបថត | ៣៣១៩ |
| -ស៊ីមផ្ទាំងគំនូរ | ៣៨១២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ផ្លាកឈ្មោះរោងចក្រ ៖"*អង្គរ ឃែនវើស ខូអិលធីឌី (ANGKOR CANVAS CO., LTD.)*"

-ទីតាំងរោងចក្រ ៖ "*ក្នុងបរិវេណរោងចក្រក្តារបន្ទះដីឥដ្ឋ ផ្លូវជាតិលេខ១ ភូមិស្តៅកន្លែង ឃុំដីឥដ្ឋ ស្រុកគៀនស្វាយ ខេត្តកណ្តាល* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន *ជាអក្សរខ្មែរមានទំហំធំជាង* និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ *ម្ចាស់រោងចក្រ នឹងត្រូវទទួល* ទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០**: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

**ប្រការ១១**: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២**: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣**: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤**: ប្រកាសលេខ ៥៣៥ ឧរថ.កឧ.ប្រក និងវិញ្ញាបនបត្របង្កើតរោងចក្រលេខ៥៧ ឧរថ.កឧ.បរ ចុះថ្ងៃទី១២.០៦.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ ផលិតស៊ីមូវបថត និង ស៊ីមផ្ទាំងគំនូរ របស់ក្រុមហ៊ុន អង្គរ យែនវើស ខូអិលធីឌី ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥**: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦**: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ:...១៧៧............កប/ប្រ.ក

# ប្រកាស

## ស្តីពីសមាសភាព និង ការប្រព្រឹត្តទៅរបស់គណៈកម្មការ ដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- អនុលោមតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដើម្បីដោះស្រាយវិវាទ ឬ បណ្តឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និង បទបញ្ជាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក ប.ស.ស និយោជក និង បេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ២.-**

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានភារកិច្ចផ្សះផ្សាវិវាទ ដែលទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គមដូចជា៖

- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងការមិនយល់ព្រម ឬ ភាពមិនត្រឹមត្រូវក្នុងការផ្តល់តាវកាលិករបបសន្តិសុខសង្គម
- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងភាពមិនប្រក្រតី នៃការផ្តល់សេវារបបសន្តិសុខសង្គម
- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិកប.ស.សចំពោះការខកខានរបស់និយោជកមិនរាយការណ៍ដើម្បីចុះឈ្មោះខ្លួនក្នុង ប.ស.ស
- បណ្តឹងតវ៉ារបស់និយោជក ចំពោះការអនុវត្តមិនត្រឹមត្រូវតាមច្បាប់ ឬ បទបញ្ជាជាធរមានរបស់មន្ត្រី ប.ស.ស
- បណ្តឹងតវ៉ាផ្សេងទៀត ដែលទាក់ទងនឹងការអនុវត្តបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៣.-**

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានសមាជិកពេញសិទ្ធិ បី រូប និង សមាជិកបម្រុង ប្រាំមួយ រូប ដូចខាងក្រោម៖

- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម
- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត
- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក (មួយរូបពេញសិទ្ធិដែលស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ជាប្រធានគណៈកម្មការ មួយរូបពេញសិទ្ធិ ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត ជាសមាជិក និង មួយរូបពេញសិទ្ធិ ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក ជាសមាជិក)

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន សមាជិកបម្រុង ដែលស្នើឡើងដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលតួនាទីជាប្រធានស្តីទី

ក្នុងករណីដែលសមាជិកគណៈកម្មការ នៃភាគីណាមួយអវត្តមាន ប្រធានគណៈកម្មការ ឬ ប្រធានស្តីទី អាចអញ្ជើញសមាជិកបម្រុងដែលតំណាងឱ្យភាគីអវត្តមានចូលរួមប្រជុំ

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ ប្រធានស្តីទី។ ហើយគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានអាណត្តិរយៈពេលមួយឆ្នាំ

ភាសារដែលត្រូវប្រើក្នុងដំណើរការរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស គឺភាសារខ្មែរ

ការប្រជុំរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវធ្វើឡើងជាការសម្ងាត់

នីតិវិធីនៃការសម្រេចរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវចេញដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

## ប្រការ ៤.-

សមាជិកនៃគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានអាយុយ៉ាងតិច២៥ ឆ្នាំ
- មានការទទួលស្គាល់ អំពីលក្ខណៈសម្បត្តិផ្នែកសីលធម៌
- បទពិសោធន៍ពាក់ព័ន្ធនឹងការងារយ៉ាងតិច០៣ ឆ្នាំ
- បរិញ្ញាបត្រផ្នែកច្បាប់ ឬ មានគុណវឌ្ឍន៍ផ្នែកច្បាប់
- មានចំណេះដឹងអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង បទបញ្ញាផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងវិស័យសន្តិសុខសង្គម ។

## ប្រការ ៥.-

ប្រធានគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវកោះអញ្ជើញភាគីប្តឹងតវ៉ាមកបំភ្លឺ និង ផ្តល់ឯកសារ ឬ ព័ត៌មានចាំបាច់ផ្សេងៗ នៅចំពោះមុខគណៈកម្មការ ។

## ប្រការ ៦.-

ភាគីប្តឹងតវ៉ា អាចបង្ហាញខ្លួន ចំពោះមុខគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយផ្ទាល់ខ្លួនដែលអាចមានអ្នកអម ឬ ដោយតំណាង ដែលទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសាមីបណ្តឹង

ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ ត្រូវបានគំរាមអោយចូលរួមផ្សះផ្សាក្នុងម៉ោងធ្វើការ និយោជក ត្រូវតែអនុញ្ញាត បន្ទាប់ពីបានទទួលលិខិតកោះអញ្ជើញ ដោយមិនឲ្យទទួលផលប៉ះពាល់ជាអវិជ្ជមាន ដល់សិទ្ធិកម្មករនិយោជិតនោះឡើយ ។

**ប្រការ ៧.-**

ក្នុងករណីដែលភាគីប្តឹងតវ៉ា ខកខានមិនបានមកបង្ហាញខ្លួនតាមការអញ្ជើញ របស់គណៈកម្មការ ដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយគ្មានមូលហេតុត្រឹមត្រូវ គណៈកម្មការអាចដំណើរការ របស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬ អាចបញ្ឈប់បណ្តឹងតវ៉ាតាមរយៈការចេញសេចក្តីសម្រេច ។

**ប្រការ ៨.-**

ក្នុងរយៈពេល១៥ ថ្ងៃធ្វើការ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវរាយការណ៍ អំពីសេចក្តីសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ជូននាយកបេឡាជាតិរបបសន្តិសុខសង្គម។ នាយក បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់ដំណឹងទៅភាគីប្តឹងតវ៉ាភ្លាម អំពីសេចក្តីសម្រេចនោះដោយផ្ទាល់ ជូនភាគីប្តឹងតវ៉ានោះនូវច្បាប់ចម្លងសេចក្តីសម្រេច ដែលមានបញ្ជាក់ត្រឹមត្រូវចំនួន០១ ច្បាប់

នាយកបេឡាជាតិរបបសន្តិសុខសង្គម អាចមានសិទ្ធិជំទាស់ ឬ បដិសេធសេចក្តីសម្រេចរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ក្នុងករណីដែលសេចក្តីសម្រេចនោះផ្ទុយនឹងច្បាប់ ឬ បទបញ្ជាជាធរមាន ហើយនាយក ប.ស.ស ត្រូវជូនដំណឹងទៅប្រធានគណៈកម្មការ ដើម្បីពិនិត្យករណី នេះសារជាថ្មី។

**ប្រការ ៩.-**

ភាគីប្តឹងតវ៉ាអាចជំទាស់ទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅនាយកបេឡាជាតិរបបសន្តិសុខសង្គម ក្នុងរយៈ ពេលប្រាំបីថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេច។ ក្នុងករណីនេះភាគីប្តឹងតវ៉ាអាចប្តឹងទៅតុលាការ មានសមត្ថកិច្ច ដើម្បីដោះស្រាយបន្ត ។

**ប្រការ ១០.-**

សេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវយកជាបានការ ហើយភាគីប្តឹងតវ៉ាត្រូវអនុវត្តតាម ប្រសិនបើគ្មានការជំទាស់រយៈពេលប្រាំបីថ្ងៃធ្វើការ ។

**ប្រការ ១១.-**

ការចំណាយសម្រាប់ការរៀបចំការប្រជុំគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវនៅក្នុងបន្ទុករបស់ ប.ស.ស ។ លាភការរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស ។

**ប្រការ ១២.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**វង្ស សុភី**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទការល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ: ១៨៧ កប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាព
## គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- ប្រកាសលេខ ១៧៧ កប/ប្រ.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស
- អនុលោមតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-** ត្រូវបានតែងតាំងសមាសភាពគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ចំនួន ០៩ រូប ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- លោក ស៊ុំ សោភ័ណ | តំណាងបេឡាជាតិរបបសន្តិសុខសង្គម | ប្រធាន |
| ២- លោក សោម ចំណាន | តំណាងនិយោជក | សមាជិក |
| ៣- លោក វង្ស សុវណ្ណ | តំណាងកម្មករនិយោជិត | សមាជិក |
| ៤- លោក ម៉េង ហុង | តំណាងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិកបំរុង |
| ៥- លោក ជាវ ប៊ុនរិទ្ធ | តំណាងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិកបំរុង |
| ៦- លោក កាំង ម៉ូនីកា | តំណាងនិយោជក | សមាជិកបំរុង |
| ៧- លោក ជាតិ ខេមរា | តំណាងនិយោជក | សមាជិកបំរុង |
| ៨- លោក ឯក សុភក្តិ | តំណាងកម្មករនិយោជិត | សមាជិកបំរុង |
| ៩- លោក សោម អូន | តំណាងកម្មករនិយោជិត | សមាជិកបំរុង |

**ប្រការ ២.-** សមាសភាពគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស អាចធ្វើការកែសម្រួលបាននៅពេលមានតម្រូវការចាំបាច់ ។

**ប្រការ ៣.-** នាយកបេឡាជាតិរបបសន្តិសុខសង្គម សមាគមនិយោជក និងកម្មករនិយោជិត សាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៩៣៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន **DUKSAN MECASYS CO., LTD.** ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ឌុកសាន មេកាស៊ីស (ខេមបូឌា)**

**DUKSAN MECASYS (CAMBODIA) CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ៦៣៤៧/០៩ E** ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **KIM SANGMOON** "តតិយជន"

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៧ ផ្លូវលេខ ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះ និង ព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាកម្មតំឡើងកុំព្យូទ័រ និង ប្រព័ន្ធកុំព្យូទ័រគ្រប់ប្រភេទ

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចាម ប្រសិទ្ធ**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម សិក្សាស្រាវជ្រាវ រុករករ៉ែ ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

អនុរដ្ឋលេខាធិការ

ហូ_សារ៉ាន់

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៩៧៩ ពណ.ចបព

ភ្នំពេញថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **អាលុយមីណា (ខេមបូឌា - វៀតណាម)**

**ALUMINA (CAMBODIA - VIETNAM) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ៦៣៦៥/០៩ E** ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :

| | | | |
|---|---|---|---|
| លោក | TRAN XUAN HOA | "តតិយជន" | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក | NGUYEN THANH TUNG | "តតិយជន" | អភិបាល |
| លោក | NGUYEN NGOC LAN | "តតិយជន" | អភិបាល |
| លោកជំទាវ | **ហ៊ុន ម៉ាណា** | "តតិយជន" | អភិបាល |
| កញ្ញា | **ឡាវ សុខហ៊ុយ** | "តតិយជន" | អភិបាល |
| លោក | TRAN THANH VAN | "តតិយជន" | អភិបាល |
| លោក | **ជា ចាន់តោ** | "តតិយជន" | អភិបាល |

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៨០.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦១ ផ្លូវលេខ ៣១៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៩៩៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៩

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រុងរឿង ធីដារតនៈ អ៊ីនធើណេសិនណាល ខូ អិលធីឌី**

**RUNG ROEUNG THIDA RATANAK INTERNATIONAL CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៤៣៦៧/០៩ P** ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **រឿង ធីដា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ប៉ូ-សារ៉ាន់

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៥០០០ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហូលីដេ អ៊ីន (ខេមបូឌា)**

**HOLIDAY INN ( CAMBODIA ) LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ៦៣៥៨/០៩E ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **LIM JOO CHUAN** ប្រធានក្រុមប្រឹក្សាភិបាល

លោក **PHUA SOO NAM** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : អគារលេខ ៨៤ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ធេសរដ្ឋមន្ត្រី

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ហ៊្វ-សារ៉ាន់

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥០០៩ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា ៖**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមខាប់ភីថល**

**Cam Capital Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ៦៣៦៤/09E ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩

មានទម្រង់ជា : ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក LEE YONG MAN ប្រធានក្រុមប្រឹក្សាភិបាល

លោក LOWE PATRICK " គតិយជន " អភិបាល

លោក HOYES JR IVAN CASTELLO " គតិយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១.០០០.០០០ ដុល្លារអាមេរិក

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៨៩ បេ វិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -អនុវត្តសកម្មភាពជាស្ថាប័នមីក្រូហិរញ្ញវត្ថុ

-ផ្តល់សេវាឥណទាន

-ផ្តល់សេវាគណនីសន្សំ បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលធនាគារមានកាតព្វកិច្ចមកដាក់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ធនាគារ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ធនាគារត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃធនាគារ ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា៖ ចាន់ សារុន ("ក្រសួងពាណិជ្ជកម្ម")

ចម្លងជូន

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

ស.ជ - ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ៥០១០ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា ៖**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុគ្គលសម្ព័ន្ធនៃក្រុមហ៊ុន CARBON CREDITED FARMING PLC, ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ិនធើណេសិនណល ហ្គ្រីន អេនើជី ខូ អិលធីឌី**

**INTERNATIONAL GREEN ENERGY CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. **៦៣៤៤**/០៩ E ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក GREGG THOMAS FRYETT "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក **អ៊ុំ សំអាង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២១ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -រោងចក្រផលិតប្រេងបៃតង ( Green Oil ) ដោយប្រើប្រាស់នូវធនធានកសិកម្ម ដើម្បីអោយកើតចេញទៅជាជីវម៉ាហ្សូត ( Biodiesel )ជីវប្លាស្ទិក (Bioplastics ) និងផលិតផលថាមពលនានា

-ផ្តល់សេវាកម្មទាក់ទងនឹងការផ្គត់ផ្គង់ ចែកចាយសំភារៈបរិក្ខារ និងផ្តល់សេវាកម្មគ្រប់គ្រងសំរាប់អតិថិជន ។

-ប្រកបអាជីវកម្មនៅកម្ពុជា រួមទាំងការទិញ លក់ ជួល ផលិត និងផ្តល់សេវាកម្មស្របច្បាប់ទាក់ទងនឹងសកម្មភាពពាណិជ្ជកម្ម ។

-ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មទាក់ទងនឹងកម្មវត្ថុអាជីវកម្មដូចបានពោលខាងលើ ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកដាក់លិខិតប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញទីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថៃ

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍-ក្រសួងសុខាភិបាល
- ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ